# **អត្ថបទព្រះធម៌**
# **ភាគ៧**




ដោយ

ព្រះតេជគុណបណ្ឌិត **ហុក សាវណ្ណ**

ព.ស. ២៥៦៥ គ.ស. ២០២១

www.hoksavann.org

# មាតិកាអត្ថបទ

១- សេចក្តីសុខកើតពីការស្ងប់
២- ចាញ់បានជាព្រះ ឈ្នះបានជាមារ
៣- តម្លៃនៃសោតាបត្តិផល
៤- សម្បត្តិរបស់ឧបាសក ៥យ៉ាង
៥- ធម៌នាំឱ្យឈ្នះមនុស្សអាក្រក់
៦- ព្រះពុទ្ធសាសនាប្រៀបមកវិទ្យាសាស្ត្រ
៧- សិទ្ធិមនុស្សផ្អែកសិទ្ធពលរដ្ឋប្រៀបមកព្រះពុទ្ធសាសនា
៨- ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃ
៩- ប្រវត្តិចិត្តរបស់មនុស្ស
១០- អត្តា ហិ អត្តនោ នាថោ ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន
១១- ព្រះពុទ្ធជាសង្គមវិទូ
១២- ធម៌ដែលនាំឱ្យប្រទេសរឹងមាំ
១៣- ប្រភេទនៃជំនះទទួលផលផ្សេងគ្នា
១៤- ធម៌ជាគ្រឿងចំរើន ៤ យ៉ាង
១៥- មគ្គប្រកបដោយអង្គ៨ ជាផ្លូវចេញចាកទុក្ខ
១៦- ពុទ្ធភាសិត ៤ បទ ដែលនាំឱ្យឈ្នះ
១៧- ប្រវត្តិព្រះពុទ្ធសាសនា ចូលមកប្រទេសកម្ពុជា

១៨- បាចអង្កាមច្រាសខ្យល់ ឈាមស្រែកស្បែកហៅ

១៩- បៀតបៀនអ្នកដទៃ នឹងជាប់ជំពាក់ពៀរ

២០- វប្បធម៌ជាគោលរបស់ជាតិ វិន័យលោកនាថជាគោលសាសនា

២១- ជំនះខ្លួនឯងជាជំនះប្រសើរបំផុត។

## ១. សេចក្តីសុខកើតពីការស្ងប់

ពុទ្ធភាសិតថា **នត្ថិ សន្តិ បរំ សុខំ** ប្រែថា សេចក្តីសុខដទៃប្រាសចាកសេចក្តីស្ងប់ពុំមានឡើយ។ បានសេចក្តីថា មានសេចក្តីស្ងប់ទើបមានសេចក្តីសុខ សេចក្តីសុខកើតពីការស្ងប់ បើពុំមានសេចក្តីស្ងប់ សេចក្តីសុខក៏ពុំមានឡើយ។ ទីណាមានការស្ងប់ទីនោះបានសេចក្តីសុខ។ មានការស្ងប់ខ្លះ សេចក្តីសុខ ក៏មានខ្លះ។ បើមានការស្ងប់ខ្ពស់ សេចក្តីសុខក៏មានខ្ពស់ ដូចជាបរមសុខរបស់ព្រះនិព្វាន កើតឡើងពីការស្ងប់ក៏ខ្ពង់ខ្ពស់។ តើស្ងប់នូវអ្វី គឺស្ងប់នូវកិលេស តណ្ហា ដែលជាធម្មជាតិធ្វើចិត្តមិនឱ្យស្ងប់ ជាពិសេស អវិជ្ជា តណ្ហា ឧបាទាន ជាកិលេសវដ្ត ជាឫសគល់ឱ្យសាងកម្មកុសល អកុសល ដែលនាំឱ្យមានវិបាកបន្តភពថ្មី វិលកើតវិលស្លាប់ក្នុងសង្សារវដ្តគ្មានទីបំផុត។ ព្រះនាមរបស់ព្រះពុទ្ធថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស គឺព្រះអង្គកំចាត់បង់កិលេសទាំងនេះអស់ហើយ ទើបព្រះអង្គមិនត្រឡប់មកកាន់ភពថ្មី គឺកើតទៀតឡើយ។ ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម សុទ្ធតែបានលះបង់នូវកិលេសតណ្ហាជាសមុច្ឆេទបហានៈ គឺលះបង់ដោយដាច់ខាត ទើបព្រះទ័យ

បរិសុទ្ធស្ងប់យ៉ាងឧក្រិដ្ឋ ទើបសម្រេចព្រះនិព្វាន បានបរមសុខថ្នាក់ឧក្រិដ្ឋដែរ។

ពិភពលោកបានទទួលស្គាល់ថា ដើម្បីឱ្យសង្គមមនុស្សបានសេចក្តីសុខ ត្រូវតែមានសន្តិភាព ពុំមានចម្បាំងប្រើហិង្សារំលោភលើសិទ្ធិគ្នា។ មានសន្តិភាព ទើបមានសេចក្តីសុខចម្រើន។ សន្តិភាព ចេញមកពីពាក្យ សន្តិ នៃពុទ្ធភាសិតនេះឯង។ ពាក្យ សន្តិ នេះហើយដែលអង្គការសហប្រជាជាតិបានយកប្រើជាសន្តិភាព ដែលកើតចេញមកពីការមិនបៀតបៀនគ្នា មិនរំលោភលើគ្នា។ ក្នុងន័យនេះហើយ ដែលគេចាត់ទុកព្រះពុទ្ធសាសនា ជាសាសនាសន្តិភាព ត្រង់ព្រះធម៌របស់ព្រះពុទ្ធបង្រៀនឱ្យមនុស្សប្រតិបត្តិធម៌អហិង្សា ការមិនបៀតបៀនគ្នា ជាមូលដ្ឋាននៃសេចក្តីសុខសន្តិភាពនៃសង្គមមនុស្ស។ តាមសេចក្តីពិតព្រះពុទ្ធព្រះបរមគ្រូ បានរកឃើញធម៌ដែលនាំឱ្យសង្គមមនុស្សរស់នៅបានសុខសាន្ត ដែលបាលីថា សន្តិ ស្ងប់ផ្លូវចិត្ត មិនមានកិលេសតណ្ហា ដែលជាហេតុនាំឱ្យបៀតបៀនគ្នានេះ មានរយៈកាលជាង ២៥០០ឆ្នាំកន្លងមកហើយ ចំណែកអង្គការសហប្រជាជាតិបានប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨ នេះទេ។ ត្រង់ន័យនេះហើយបានជា អង្គការ

សហប្រជាជាតិបានទទួលស្គាល់បុណ្យពិសាខបូជារបស់ ព្រះពុទ្ធសាសនា ជាបុណ្យអន្តរជាតិ ព្រោះព្រះធម៌របស់ព្រះពុទ្ធ ត្រង់ធម៌សន្តិ ការស្ងប់ មិនធ្វើអំពើបាប មិនប្រើអំពើហិង្សា ការបៀនបៀនគ្នានេះទុកជាគ្រឹះមូលដ្ឋាននៃសន្តិភាពពិភពលោក ស្របនឹងសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

បើចិត្តរបស់មនុស្សក្នុងសង្គមពុំស្ងប់ នាំឱ្យបៀតបៀនគ្នា សង្គមមនុស្សពុំបានសុខឡើយ ប្រៀបដូចទូក កប៉ាល់ នាវាដែលបើកបរក្នុងទន្លេ ក្នុងសមុទ្រ បើទឹកពុំស្ងប់ ដោយមានរលកបក់បោក នាំឱ្យមានភ័យដល់អ្នកជិះ ព្រោះនាវាអាចលិចដោយសារទឹកពុំស្ងប់នេះឯង។ យ៉ាងណាមិញ បើកាយ វាចា ចិត្តរបស់មនុស្សពុំស្ងប់ ប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ នឹងនាំឱ្យមានទុក្ខភ័យដល់អ្នកដទៃទៀតដែលជាសមាជិករបស់សង្គម។ ការទាស់ទែងខ្វែងគំនិតគ្នា រហូតប្រើហិង្សាច្បាំងគ្នាក្នុងពិភពលោក ដោយសារកាយ វាចា ចិត្ត របស់សង្គមមនុស្សពុំស្ងប់នេះឯង។ បើគេអនុវត្តតាមមាគ៌ាសន្តិភាពរបស់ព្រះពុទ្ធសាសនា ពិភពលោកពុំច្បាំងគ្នាទេ បើមានបញ្ហាកើតឡើង បានដោះស្រាយដោយសន្តិវិធី ដោយសារទាំងអស់គ្នាមានចិត្តស្ងប់នេះឯង។

ចំពោះប្រទេសសកម្ពុជា មានភព្វសំណាងណាស់ ដោយគោរពព្រះពុទ្ធសាសនាថេរវាទ ដែលមានពាក្យប្រៀនប្រដៅដ៏ល្អបរិសុទ្ធ ជាមាគ៌ាអាចជួយសង្គមខ្មែរឱ្យបានសុខសន្តិភាព និងចម្រើនលូតលាស់គ្រប់វិស័យ មានវិស័យសីលធម៌ជាដើម បើខ្មែរគ្រប់ឋានៈនាំគ្នាសិក្សាឱ្យយល់ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយប្រតិបត្តិតាមឱ្យបានត្រឹមត្រូវ។ កន្លងមក ព្រះពុទ្ធសាសនាបានត្រូវផ្លូវនយោបាយ គ្របសង្កត់ ពុំអាចចេញមុខបំពេញមុខនាទីរបស់ខ្លួន បានជាធ្វើឱ្យប្រទេសកម្ពុជារងទុក្ខវេទនា បែកបាក់សាមគ្គីគ្នា។ ព្រះពុទ្ធសាសនាមិនត្រឹមតែបង្រៀនមនុស្សលោកឱ្យស្រឡាញ់ខ្លួន ស្រឡាញ់គ្រួសារខ្លួន និងស្រឡាញ់ជាតិខ្លួនប៉ុណ្ណោះទេ ព្រះអង្គបានបង្រៀនឱ្យស្រឡាញ់មនុស្សជាតិទូទៅ។ លើសពីនេះទៀត ឱ្យស្រឡាញ់សត្វតិរច្ឆាន មិនឱ្យបៀតបៀន មិនឱ្យសម្លាប់ទៀតផង។ បានសេចក្ដីថា មិនត្រឹមតែឱ្យគោរពសិទ្ធិមនុស្សទេ គឺឱ្យគោរពសិទ្ធិសត្វតិរច្ឆានថែមទៀត ដែលមានកម្រឹតខ្ពស់ជាងសិទ្ធិមនុស្សនៃ អង្គការសហប្រជាជាតិ។ មានសំណាងមួយទៀត ត្រង់នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ កាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ពុំមែនជារបបកុម្មុនិស្ត ហើយពុំមែនជារបស់ផ្ដាច់ការ។ បើខ្មែរគ្រប់ឋានៈ គោរពតាមរដ្ឋធម្មនុញ្ញ

នៃរបបនេះឱ្យបានត្រឹមត្រូវមានយុត្តិធម៌ក្នុងសង្គម ទើបខ្មែររួមសាមគ្គីគ្នា មានឯកភាពជាតិ សត្រូវឈ្លានពានពីបរទេសនឹងត្រូវបរាជ័យ៕

## ២. ចាញ់បានជាព្រះ ឈ្នះបានជាមារ

ពាក្យថា "ចាញ់បានជាព្រះ ឈ្នះបានជាមារ" នេះ ជាពាក្យកើតចេញមកពីអ្នកកាន់ព្រះពុទ្ធសាសនា ពោលឡើងនៅពេលដែលមានមនុស្សទាស់ទែងខ្វែងគំនិតគ្នា ឱ្យចេះអត់ឱនគ្នា កុំប្រើអំពើហិង្សា។ សុខចិត្តចាញ់ឱ្យគេឈ្នះទៅចុះ ចាញ់ហ្នឹងបានជាព្រះ ឯអ្នកឈ្នះនឹងបានជាមារទេ។

ពាក្យថា "ចាញ់បានជាព្រះ" គឺចាញ់ក្នុងន័យថា ពុំប្រព្រឹត្តធ្វើអំពើអាក្រក់ ខុសច្បាប់ផ្លូវធម៌ និងខុសច្បាប់សង្គម ដូចជាជនពាល។ ពាក្យថាព្រះនេះ បើសំដៅយកព្រះពុទ្ធត្រាស់ដឹង គឺព្រះអង្គលះបង់នូវគ្រឿងសៅហ្មងក្នុងព្រះទ័យរបស់ព្រះអង្គដែល ជាហេតុនាំឱ្យសាងបាបកម្មអស់ហើយ ទើបបានត្រាស់ជាព្រះពុទ្ធ។ ពាក្យថា មារ បើពោលជាធម្មាធិដ្ឋានបានដល់សភាវៈសម្លាប់សភាវៈបៀតបៀន បង្អាក់ដំណើរមិនឱ្យមនុស្សសត្វបានសេចក្តីសុខ។ បើពោលជាបុគ្គលាធិដ្ឋាន បានដល់បុគ្គលដែលបៀតបៀនបុគ្គលដទៃមិនឱ្យគេបានសេចក្តីសុខ។ ក្នុងព្រះពុទ្ធសាសនា មារមាន ៥ យ៉ាងគឺ ខន្ធមារ មារគឺខន្ធ៥ គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ, កិលេសមារ មារគឺកិលេស បានដល់ លោភៈ ទោសៈ មោហៈ បច្ចុមារ មារគឺសេចក្តីស្លាប់ អភិសង្ខារមារ មារគឺអភិសង្ខារ

បានដល់បុណ្យបាប ទេវបុត្តមារ មារគឺទេវបុត្ត បានដល់សង្ខិលេស។ ព្រះអង្គឈ្នះមារទាំង៥នេះ ទើបឆ្លងផុតពីសេចក្តីទុក្ខក្នុងវដ្តសង្សារ។ ពាក្យខ្មែរក៏បានពោលថា ចាញ់ដើម្បីឈ្នះ គឺចាញ់មិនសាងអាក្រក់ តែនឹងបានទទួលជ័យជំនះ ដោយសារអំពើល្អរបស់ខ្លួន។

ពាក្យថា "ឈ្នះបានជាមារ" បើនិយាយពីមារមានរូប បានដល់បុគ្គលពាលដែលតែងតែប្រព្រឹត្តធ្វើអំពើអាក្រក់ តាមព្យាបាទបៀតបៀនអ្នកដទៃ ធ្វើឱ្យគេមានទុក្ខ។ មារដែលព្រះពុទ្ធបានឈ្នះ គឺមារដែលស្ថិតនៅក្នុងព្រះទ័យព្រះអង្គ មានលោភៈ ទោសៈ មោហៈ ជាដើម។ បានជាលោភៈ ចាត់កិលេសតណ្ហានេះជាមារ ព្រោះកិលេសតណ្ហានេះជាហេតុជាបច្ច័យបិទបាំង ឬជាអន្ទាក់មិនឱ្យព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធបាន។ គេចាត់ទុកមនុស្ស និងប្រទេសដែលបៀតបៀន និងឈ្លានពានគេជាមារ ព្រោះធ្វើឱ្យមនុស្ស និងប្រទេសដទៃមានទុក្ខ ដោយការរំលោភឈ្លានពានរបស់ខ្លួន។ បុគ្គលដែលជាមារនេះ ពេលខ្លះបានទទួលជ័យជំនះក្នុងរយៈពេលខ្លី ទីបំផុតត្រូវទទួលបរាជ័យវិញ។ ប្រទេសនានាក្នុងពិភពលោក និងអង្គការសហប្រជាជាតិតែងបញ្ញត្តិច្បាប់រៀងៗខ្លួនដើម្បីកំចាត់មនុស្សជាមារនេះ។ បើនិយាយតាមភាសាមនុស្សលោកសព្វថ្ងៃនេះ មនុស្សមារ គឺមនុស្សរំលោភសិទ្ធិមនុស្សនេះឯង។

ការលួចកាប់សម្លាប់ ការលួចប្លន់ ការរំលោភបៀតបៀនគ្រប់បែបយ៉ាង ដែលជាអំពើរបស់ជនសាមញ្ញក្តី របស់អ្នកនយោបាយក្តី សុទ្ធសឹងជាអំពើពាល ចាត់ចូលជាបក្សពួកមារ ព្រោះបៀតបៀនធ្វើឱ្យសង្គមមានទុក្ខ។ ធម្មជាតិរបស់មារ ទោះមានរូបក្តី ឥតរូបក្តី តែងបញ្ចេញអំពើអាក្រក់របស់ខ្លួន តែទីបំផុតត្រូវបរាជ័យ និងបាត់បង់ទៅវិញ ដូចពុទ្ធភាសិតថា ឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ។ ព្រះពុទ្ធជាតំណាងសេចក្តីល្អ ឯមារជាតំណាងសេចក្តីអាក្រក់។ ព្រះពុទ្ធជាបុគ្គលឈ្នះមារ ឯមារត្រូវទទួលបរាជ័យ ដោយអំពើអាក្រក់របស់ខ្លួន។

ពាក្យថា "ចាញ់បានជាព្រះ ឈ្នះបានជាមារ" នេះ ពុំមានឧបសគ្គក្នុងការថែរក្សាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីខ្មែរទេ ព្រោះសព្វថ្ងៃនេះ ពិភពលោកមានច្បាប់ គ្រប់ប្រទេសទាំងអស់ត្រូវគោរពច្បាប់ បើប្រទេសណាមួយរំលោភលើប្រទេសមួយទៀតជាសមាជិក ជាអំពើខុសច្បាប់។ ប្រទេសដែលត្រូវគេឈ្លានពាននោះមានសិទ្ធិស្របច្បាប់ក្នុងការការពារប្រទេសរបស់ខ្លួន ដោយមធ្យោបាយផ្សេងៗ ហើយអាចប្តឹងដល់អង្គការសហប្រជាជាតិឱ្យគេជួយធ្វើអន្តរាគមន៍ផង។ ពាក្យថា ចាញ់បានជាព្រះ ឈ្នះបានជាមារ ពុំមែនមានន័យថា ប្រទេសណាមួយឈ្លានពាន

ប្រទេសកម្ពុជា ត្រូវអ្នកដឹកនាំខ្មែរ និងពលរដ្ឋខ្មែរឱបដៃមើល បណ្ដោយឱ្យបរទេសឈ្លានពានតាមអំពើចិត្តនោះឡើយ ផ្ទុយទៅវិញ ត្រូវអ្នកដឹកនាំ និងពលរដ្ឋខ្មែរសាមគ្គីគ្នា ប្រឆាំង និងការឈ្លានពាននេះ ដើម្បីការពារអ្វីៗទាំងអស់ របស់ខ្មែរមានទឹកដីជាដើម ទោះបីប្រើសន្តិវិធីក្តី យុទ្ធវិធីក្តី ជាអំពើស្របច្បាប់ ជាសិទ្ធិការពារខ្លួនពីប្រទេសរំលោភដែលជាមារ មិនទាស់ខុសនឹងប្រធានបទខាងលើនេះឡើយ។ តាមព្រះពុទ្ធសាសនា ដំណោះស្រាយគ្រប់បញ្ហាទំនាស់ទាំងអស់ បើអាចប្រើសន្តិវិធីបានជាការប្រពៃណាស់ ព្រោះថាការប្រើ យុទ្ធវិធីទាំងអ្នកចាញ់ ទាំងអ្នកឈ្នះតែងតែខូចខាតទាំងទ្រព្យសម្បត្តិទាំងជីវិតមនុស្ស។ ការប្រើសន្តិវិធី តាមផ្លូវច្បាប់អាចធ្វើឱ្យភាគីទាំងអ្នកចាញ់ និងអ្នកឈ្នះមិនខូចខាត ហើយធ្វើឱ្យគូភាគីទាំងសងខាងសុខ ចិត្តទាំងងស់គ្នា។ ជំនះប្រកប ដោយយុត្តិធម៌ជាជំនះប្រសើរថ្លៃថ្លា៕

## ៣. តម្លៃនៃសោតាបត្តិផល

ពាក្យថា សោតាបត្តិផល ប្រសើរជាងអំណាចនៅលើផែនដី និងសេចក្តីសុខក្នុងស្ថានសួគ៌ ជាពាក្យបំព្រួញពីពុទ្ធភាសិតថា **បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ** ប្រែថាៈ សោតាបត្តិផលប្រសើរជាងឯករាជ្យលើផែនដី ជាងទៅកាន់ស្ថានសួគ៌ និងប្រសើរជាងអធិបតេយ្យនៅក្នុងលោកទាំងមូល។

ហេតុដែលនាំឱ្យសំដែងគាថានេះឡើង ដោយមានរឿងជាសង្ខេបថា បុត្តសេដ្ឋីម្នាក់ឈ្មោះ **កាលៈ** បានត្រូវឪពុកជួលឱ្យទៅរក្សាឧបោសថសីល ដោយឱ្យរង្វាន់ ១០០ កហាបណៈ។ យុវជនកាលៈ បានទៅវត្ត តែពុំបានរក្សាឧបោសថសីលទេ ទៅពួនសម្ងំដេកនៅទីស្ងាត់មួយ។ លុះព្រលឹមឡើងប្រញាប់ទៅផ្ទះវិញដើម្បីទារយកថ្លៃឈ្នួល ១០០ កហាបណៈពីឪពុក។ ថ្ងៃក្រោយទៀត អនាថបិណ្ឌិកសេដ្ឋី ជាឪពុកបានជួលកាលៈជាកូនឱ្យទៅស្តាប់ធម៌ម្តងឱ្យចាំបានតែមួយបទនឹងផ្តល់ឱ្យប្រាក់ចំនួន ១០០០ កហាបណៈ។ ពេលកាលៈ កំពុងស្តាប់ធម៌ ព្រះពុទ្ធបានជ្រាបព្រះអង្គធ្វើមិនឱ្យកាលៈចាំធម៌ ណាមួយសោះ។ ដោយចង់បានប្រាក់ យុវជនកាលៈ ខំព្យាយាមស្តាប់ដោយយកចិត្តទុកដាក់

ដោយមាន ឧបនិស្ស័យពីមុនមកផង យុវជននោះ ក៏បានសម្រេចសោតាបត្តិផលក្នុងពេលនោះទៅ។ លុះព្រលឹមឡើង ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បាននិមន្តទៅផ្ទះសេដ្ឋីដើម្បីទទួលភត្ត ដោយយុវជនកាលៈ ទៅជាមួយផង។ បន្ទាប់ពីភត្តកិច្ចចប់ សេដ្ឋីបានលើកប្រាក់១០០០ កហាបណៈ ប្រគល់ទៅឱ្យកូនរបស់ខ្លួនតាមការសន្យាឱ្យទៅស្តាប់ធម៌។ យុវជនជាកូនមានការអៀនខ្មាសដើរគេចចេញមិនទទួលយកឡើយ។ សេដ្ឋីបានក្រាបទូលព្រះពុទ្ធជាម្ចាស់អំពីរឿងរ៉ាវដែលខ្លួនបានជួលកូនឱ្យទៅស្តាប់ធម៌ដើម្បីលះបង់នូវមិច្ឆាទិដ្ឋិ ដោយឱ្យថ្លៃឈ្នួល តែពេលនេះហាក់ដូចជាមានអាការៈប្លែក មិនទទួលយកប្រាក់នោះឡើយ។ ព្រះពុទ្ធមានព្រះពុទ្ធដីកាថា កូនរបស់អ្នកបានសម្រេចសោតាបត្តិផលហើយ ទើបព្រះអង្គសំដែងគាថា ដូចពោលមកខាងដើមថា សោតាបត្តិផល ប្រសើរជាងឯករាជ្យនៅលើផែនដី ជាងទៅកាន់ស្ថានសួគ៌ និងប្រសើរជាងអធិបតេយ្យនៅក្នុងលោកទាំងមូលនេះឯង។

អ្នកដែលបានសម្រេចសោតាបត្តិផលឈ្មោះថា សោតាបន្នបុគ្គល ជាអរិយបុគ្គលថ្នាក់ទី១ ក្នុង បណ្តាអរិយបុគ្គលទាំង៤ពួក។ ថ្នាក់សោតា លះបង់បានធម៌៣យ៉ាងដោយដាច់ខាត ក្នុងបណ្តាសំយោជនកិលេស១០យ៉ាង។ ធម៌ ៣ យ៉ាងនោះគឺ

សក្កាយទិដ្ឋិគំនិតយល់ថាជាកាយរបស់ខ្លួន គំនិតយល់ខុសនេះ ថ្នាក់សោតាលះបង់បាន ដោយប្រាជ្ញាជាលោកុត្តរៈ កើតឡើង ឃើញច្បាស់ថា រូបកាយដែលជាខន្ធ៥នេះ មានសភាពពុំទៀង ជាទុក្ខ និងជាអនត្តា ពុំមែនជាតួខ្លួនឡើយ។ វិចិកិច្ឆា សេចក្តីសង្ស័យក្នុងខន្ធ៥ ថ្នាក់សោតាលោកលះបង់បាន គឺប្រាជ្ញាថ្នាក់វិបស្សនាបានកើតឡើងឃើញថាខន្ធ៥ជាទុក្ខគ្រប់កាលទាំងបី ឱ្យតែកើតឡើងនៃខន្ធ៥ គឺជាទុក្ខ។ សីលព្វតបរាមាសៈ ប្រែថា កាស្ទាបអង្អែលនូវសីល និងវត។ បរាមាសៈ ការស្ទាបអង្អែលបានន័យថា ការប្រកាន់ វតៈ ការប្រព្រឹត្ត សីលៈ ជាប្រក្រតី រួមសេចក្តីមក សីលព្វតបរាមាសៈ ប្រែថា ការប្រកាន់ការប្រព្រឹត្តជាប្រក្រតី។ បានសេចក្តីថា កាលសម័យដើម សាសនាហិណ្ឌូ បានប្រព្រឹត្តតាមអាការៈសត្វឆ្កែ និងសត្វគោ ហៅថា វតឆ្កែនិងវតគោ ដោយយល់ថា ការធ្វើត្រាប់តាមសត្វទាំងនេះ ពួកគេនឹងបានសុខ។ ការប្រព្រឹត្តបែបនេះ ព្រះពុទ្ធបានសំដែងថា ជាការប្រព្រឹត្តគ្មានបានផលអ្វីឡើយ។ ថ្នាក់សោតា បានលះបង់នូវការប្រព្រឹត្តបែបនេះ សូម្បីលោកប្រតិបត្តិត្រឹមត្រូវតាមសីល សមាធិ បញ្ញា ហើយក៏ដោយ ក៏លោកចាត់ទុកការប្រតិបត្តិនេះគ្រាន់តែ ជាមធ្យោបាយចេញចាកទុក្ខប៉ុណ្ណោះ ពុំមែនជាកម្មវត្ថុនៃការប្រកាន់ឡើយ។ អរិយបុគ្គលទី១

ថ្នាក់សោតាបន្នបុគ្គលនេះ នឹងរួចចាកទុក្ខ ផុតកើតចាស់ឈឺស្លាប់ យ៉ាងយូរបំផុតត្រឹមតែ៧ជាតិ។ ដូច្នេះសម្បត្តិសោតានេះជាសម្បត្តិដ៏ខ្ពង់ខ្ពស់លើសសម្បត្តិនានាក្នុងលោក។

ចំពោះប្រទេសឯករាជ្យវិញ គ្រាន់តែមានអំណាចគ្រប់គ្រងខ្លួនដោយខ្លួនឯង គ្មានបរទេសត្រួតត្រាពីលើប៉ុណ្ណោះ ពុំមែនបានសុខសន្តិភាពរហូតដោយគ្មានបញ្ហាឡើយ ព្រោះអ្វីៗស្ថិតនៅក្នុងភាពពុំទៀង។ ការទៅកើតក្នុងស្ថានសួគ៌ ទោះបីសោយទិព្វសម្បត្តិទាំង១០ប្រការ ប្រសើរជាងស្ថានមនុស្សក៏ពិតមែន ប៉ុន្តែជាស្ថានស្ថិតក្រោមអំណាចត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ដូចស្ថានមនុស្សដែរ។ ចំណែកអធិបតេយ្យ គឺអំណាចក្នុងលោក គឺអំណាចត្រួតត្រាលើសង្គមតូចសង្គមធំ រហូតដល់សហគមន៍ពិភពលោក ក៏មិនប្រសើរជាងអរិយបុគ្គលថ្នាក់សោតាបន្នបុគ្គលឡើយ ព្រោះអំណាចទាំងនោះ ពុំអាចកំចាត់ការកើតចាស់ឈឺស្លាប់បានឡើយ៕

## ៤. សម្បត្តិរបស់ឧបាសក ៥ យ៉ាង

ពាក្យថា ឧបាសក ប្រែថា អ្នកចូលទៅជិតព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។ បើស្ត្រីហៅថា ឧបាសិកា។ ការដល់នូវត្រៃសរណគមន៍ ប្រកបដោយលក្ខណៈ៣យ៉ាង គឺៈ សទ្ធា បញ្ញា និងជីវិតបរិច្ចាគ គឺជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ ជឿព្រះធម៌ជាមាគ៌ាចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិល្អតាមធម៌វិន័យពិតមែន ហើយហ៊ានលះបង់ជីវិតពុំលះបង់ព្រះរតនត្រ័យឡើយ។ ដើម្បីឱ្យទៅជាឧបាសក ឧបាសិកាពេញលក្ខណៈ ត្រូវលះបង់វិបត្តិ៥យ៉ាង ហើយត្រូវប្រកបដោយសម្បត្តិ៥យ៉ាង។ សម្បត្តិឧបាសក គឺជាធម្មជាតិញ៉ាំងសទ្ធា និងសីលនៃឧបាសកឱ្យពេញបរិបូរណ៍ និងបរិសុទ្ធប្រពៃឈ្មោះថា សម្បត្តិមាន៥យ៉ាង។

១- **សទ្ធោ ហោតិ** ឧបាសកមានជំនឿជាក់ច្បាស់ និងរឹងមាំក្នុងគុណព្រះរតនត្រ័យ។ បានសេចក្តីមកទៀតថា ជំនឿគុណព្រះរតនត្រ័យគឺជំនឿលើកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។ ជំនឿជាអាទិភាពទីមួយ ក្នុងដំណើរជីវិតរបស់មនុស្សសត្វ គឺបើមានជំនឿអាចដឹកនាំជីវិតទៅរកផ្លូវត្រូវ។ បានសេចក្តីថា មុននឹងប្រតិបត្តិតាមព្រះធម៌ ពុទ្ធសាសនិកជនតែងតែមានជំនឿលើព្រះពុទ្ធជាមុន។

២- **សីលវា ហោតិ** ឧបាសកមានសីល បានសេចក្តីថា បន្ទាប់ពីមានជំនឿលើព្រះពុទ្ធហើយ ទើបអនុវត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ មានការសមាទានសីលជាដើម។ សីល ការវៀរចាកមិនធ្វើអំពើអាក្រក់ដោយកាយ និងវាចាជាគុណធម៌សំខាន់ចាំបាច់របស់មនុស្សសត្វ។ បើមនុស្សពុំមានគុណធម៌ គឺសីលការរស់នៅរបស់ពួកគេពុំមានតម្លៃអ្វីឡើយ ថែមទាំងបង្កើតសេចក្តីទុក្ខឱ្យដល់សង្គមមនុស្សផង។ មនុស្សដែលមានអារ្យធម៌ខ្ពស់ គឺមនុស្សមានគុណធម៌គឺសីល ដោយប្រតិបត្តិសីល៥ គឺការវៀរចាកមិនសម្លាប់ មិនលួចប្លន់ មិនប្រព្រឹត្តកន្លងប្រពៃណីកូនប្រពន្ធអ្នកដទៃ មិនកុហកឆបោក និងមិនផឹកទឹកស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ ដែលនាំឱ្យបៀតបៀនអ្នកដទៃ។ ការមានសីលធម៌នេះ ពុំមែនសម្រាប់តែឧបាសកអ្នកកាន់ព្រះពុទ្ធសាសនាឡើយ តែសម្រាប់មនុស្សទូទៅ ព្រោះការមានសីលធម៌នេះ គឺជាការគោរពសិទ្ធិមនុស្ស។

៣- **អកោតុហលមង្គលិកោ ហោតិ** ឧបាសកមិនជឿមង្គលភ្ញាក់ផ្អើលថាឱ្យសុខចម្រើន។ បានសេចក្តីថា មិនមានជំនឿខុសទៅលើហេតុការណ៍ណាមួយ ដែលកើតឡើងតាមច្បាប់ធម្មជាតិ ដូចជា រន្ទះបាញ់ញ័រផែនដី ភ្នំភ្លើងផ្ទុះជាដើម ដែលពី

ដើមយល់ថា មានវត្ថុស័ក្តិសិទ្ធិបណ្តាលឱ្យកើតឡើង ជំនឿនេះបានចុះខ្សោយបន្ទាប់ពីវិទ្យាសាស្ត្របានបង្ហាញហេតុផល។ ជំនឿខុសមួយផ្នែកទៀត គឺកើតពីមនុស្សបង្កើតឡើងដោយការបោកប្រាស់ដើម្បីលាភសក្ការៈ ដូចជាយកព្រះពុទ្ធរូបតូចៗទៅលួចកប់ ហើយទៅកាយយកមកថាព្រះផុស តាំងខ្លួនថាសម្តេចជួន ណាត ដឹកជាតិ តាំងខ្លួនថាខ្លួនជាព្រះសិអារ្យមេត្រីយ៍ រហូតតាំងខ្លួនជាព្រះពុទ្ធអង្គ។ ជំនឿខុសនាំឱ្យប្រព្រឹត្តខុស នឹងនាំឱ្យកើតសេចក្តីអន្តរាយច្រើនយ៉ាងណាស់ ដែលមនុស្សទូទៅជាពិសេសឧបាសកឧបាសិកាត្រូវលះបង់នូវជំនឿខុសបែបនេះ។ ត្រង់នេះ ព្រះពុទ្ធបានសំដែងក្នុងកាលាមសូត្រប្រកាសប្រាប់មនុស្សសត្វ កុំឱ្យជឿពាក្យនិយាយតៗគ្នា កុំឱ្យជឿអការៈខាងក្រៅ កុំឱ្យជឿត្រឹមតែពាក្យសំដីជាវោហាសាស្ត្រជាដើម មុននឹងជឿថាជាយ៉ាងណាត្រូវពិចារណា និងពិសោធឱ្យបានល្អិតល្អន់ជាមុនសិន។ ពាក្យខ្មែរក៏មាននិយាយថា កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្តមណ៍ កុំទុកចិត្តអភិប្រាយ។ ពាក្យអភិប្រាយខាងចុងនេះ គឺកុំទុកចិត្តអ្នកនិយាយប្រាជ្ញព្រោកខាងក្រៅថាជាការពិតត្រូវពិចារណាឱ្យដឹងហេតុផលច្បាស់លាស់។

៤- **កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកប្រកាន់ជឿថា កម្មជាកុសល និងអកុសលតែងតែឱ្យផល មិនប្រកាន់ជឿថា មង្គលមានឫក្សពារ វេលាជាដើមឱ្យផលឡើយ។ បានសេចក្ដីថា ឧបាសកជឿតែកម្មផល ល្អអាក្រក់របស់ខ្លួន មិនជឿងឫក្សពារ វេលា គឺមិនជឿថ្ងៃខែឆ្នាំ ថាឱ្យផលល្អអាក្រក់ដល់ខ្លួនឡើយ។ មិនជឿងថ្ងៃលិចថ្ងៃអណ្ដែត ថ្ងៃនេះល្អ ថ្ងៃនេះអាក្រក់ឡើយ។ គាថាមួយពោលថា ពេលណាមនុស្សសត្វទាំងឡាយប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះឈ្មោះថា ជានក្ខត្តឫក្សល្អជាមង្គលល្អ ជាខណៈល្អ ជាយាមល្អ។ ពាក្យនេះជាការពិតណាស់ ឧទាហរណ៍ ម៉ោងនេះឧបាសកម្នាក់ ទៅសមាទានសីល តែងបានសុខកាយសប្បាយចិត្ត ដោយគ្មានទោសសត្រូវនិងអ្នកដទៃឡើយ ម៉ោងដដែលនោះ មនុស្សម្នាក់ទៅលួចប្លន់អ្នកដទៃត្រូវប៉ូលីសចាប់ចងឱ្យតុលាការកាត់ទោស។ ដូច្នេះ សុខទុក្ខនោះដោយអំពើរបស់ខ្លួនពុំមែនដោយពេលវេលានោះឡើយ។

៥- **ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនា ហើយគោរពបូជាឡើយ។ ទក្ខិណេយ្យបុគ្គលដែលមានចិត្តបរិសុទ្ធដូចជាព្រះអរហន្ត មានតែក្នុងព្រះពុទ្ធ

សាសនា ឯសាសនាដទៃពុំមានឡើយ ព្រោះមិនប្រតិបត្តិតាមអដ្ឋង្គិកមគ្គ ដែលជាផ្លូវនៃសេចក្ដីបរិសុទ្ធ។

ជនដែលប្រតិបត្តិតាមធម៌ទាំង៥ប្រការនេះ ចាត់ជាឧបាសកឧបាសិកា មានគុណធម៌ពេញលក្ខណៈ អាចឱ្យសង្គមមានការរីកចម្រើនលូតលាស់ខាងសីលធម៌ផង និងខាងសាមគ្គីភាពផង។

## ៥. ធម៌នាំឱ្យឈ្នះមនុស្សអាក្រក់

ពុទ្ធភាសិត សំដែងអំពីជំនះលើបុគ្គលប្រព្រឹត្តអាក្រក់ គឺ បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹង ដោយពុំក្រោធខឹងតប គប្បី ឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ ដោយការឱ្យ គប្បីឈ្នះមនុស្សនិយាយពាក្យពុំពិតដោយពាក្យពិត នេះចេញមកពីគាថាថា **អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ** ពាក្យថាបុគ្គលគប្បីឈ្នះ មនុស្សក្រោធខឹង ដោយពុំក្រោធ ខឹងតប បានសេចក្តីថា បុគ្គលណាម្នាក់បានទប់ចិត្តពុំក្រោធខឹងតប វិញ ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយដែលបានក្រោធខឹង ចំពោះខ្លួន ដោយវិធីអត់ឱន ពុំខឹងតបវិញ ដោយប្រើចិត្តមេត្តា។ ការ ប្រើវិធីនេះ ពុំយូរប៉ុន្មានជននោះ អាចស្រាលចិត្តអន់កំហឹង ឬបាត់ ខឹងតែម្តង ដោយឃើញភាពពុំមានប្រតិកម្មតបតមកខ្លួនវិញ។ បើ ខឹងតបវិញ ហាក់ដូចជាយកអុសទៅដាក់បន្ថែម ក្នុងភ្លើងដែល កំពុងឆេះសន្ធោសន្ធៅ។ ពាក្យថា ឈ្នះ គឺឈ្នះត្រង់ពុំខឹងតបនេះ ឯង។ ប៉ុន្តែការបង្អន់កំហឹងចំពោះអ្នកខឹង ដោយមិនតបតដោយ កំហឹងនោះ បានចំពោះតែបុគ្គលខ្លះ និងចំពោះតែកំហឹងស្រាលៗ បើកំហឹងនោះឡើងដល់កម្រិតខ្ពស់ហើយ ពុំអាចបង្អន់កំហឹង

នោះឡើយ។ ប៉ុន្តែអ្នកអត់ឱនបានលទ្ធផលសំខាន់ត្រង់មិនចង់ឱ្យមានការចងពៀរនឹងគ្នាតទៅមុខទៀត។ អ្នកដែលមានកំហឹងមកអំពីមានអារម្មណ៍ណាមួយពុំគាប់ចិត្តរបស់ខ្លួន។ គេអាចលះកំហឹងបាន ដោយការពិចារណាទោសនៃកំហឹងនោះជាមួយនឹងគុណសម្បត្តិនៃធម៌មេត្តា។ ការទាស់ទែងខ្វែងគំនិតគ្នារហូតដល់ប្រើហិង្សាមកអំពីសេចក្ដីក្រោធ ដែលជាក្រុមរបស់ទោសៈនេះឯង។ ពុទ្ធសាសនា ពោលថា សង្គមតូចសង្គមធំបើមានការបៀតបៀនគ្នាហើយ សង្គមនោះពុំបានសេចក្ដីសុខសន្តិភាពឡើយ។ តាមន័យនេះ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា គួរខ្មែរគ្រប់គ្នាកុំប្រើធម៌ហិង្សាទោះបីមានទំនាស់គ្នាក្នុងគ្រួសារក្ដី ក្នុងបញ្ហានយោបាយរបស់ប្រទេសជាតិក្ដី គួរប្រើវិធីសម្រុះសម្រួលគ្នាចរចាគ្នាដោយសន្តិវិធី រក្សាឯកភាពជាតិ ដើម្បីរស់នៅជាមួយគ្នាដោយសុខសាន្ត រក្សាអត្តសញ្ញាណជាតិ។ គួរយកអតីតកាលជាមេរៀនសម្រាប់រៀបចំអនាគត ឱ្យចម្រើនរុងរឿងនៃប្រទេសកម្ពុជាមាតុភូមិ។ តាមពុទ្ធភាសិតដូចពោលមកហើយនេះ សូមកុំយល់ច្រឡំអំពីពាក្យថា ពុំខឹងតបត និងពាក្យថាសិទ្ធិការពារកម្មសិទ្ធិរបស់ខ្លួន។ ការពុំខឹងតបតពុំមែនបានន័យថា គេរំលោភសិទ្ធិមានការរំលោភយកទឹកដីជាដើម ពុំការពារ បណ្ដោយឱ្យគេយកតាមចិត្តនោះឡើយ។

ផ្ទុយទៅវិញ ពុទ្ធសាសនាបានសំដែងឱ្យថែរក្សារបស់ដែលមាន និងស្វែងរក របស់ដែលបានបាត់បង់ដែលបាលីថាអារក្ខសម្បទា។

ពាក្យថា គប្បីឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ។ ពាក្យនេះមានន័យស្រដៀងគ្នា នឹងពាក្យកុំតបតដោយកំហឹងចំពោះមនុស្សមានកំហឹង។ តាមធម្មតា មនុស្សអាក្រក់បើធ្វើអាក្រក់តបមនុស្សអាក្រក់នឹងធ្វើអាក្រក់កាន់តែខ្លាំងឡើង។ បើគេធ្វើអាក្រក់ ត្រូវព្យាយាមធ្វើល្អតបវិញជាមួយនឹងការជួយណែនាំឱ្យលះបង់អំពីអាក្រក់ហើយចាប់ផ្តើមសាងល្អវិញ។ បើមនុស្សនោះមានគំនិតពាលខ្លាំង នឹងមិនអាចកែគំនិតអាក្រក់មកល្អវិញបានឡើយ។ ក្នុងមង្គលសូត្រនៃគម្ពីរពុទ្ធសាសនា បានហាមកុំឱ្យសេពគប់បុគ្គលពាលព្រោះបុគ្គលពាលទោះបីធ្វើល្អយ៉ាងណា ក៏បុគ្គលពាលមិនឱ្យសុខដែរ ត្រូវជៀសវាងចេញឱ្យឆ្ងាយ។ ប៉ុន្តែជ័យជំនះ ក្នុងពុទ្ធភាសិតនេះ គឺអ្នកប្រព្រឹត្តអាក្រក់ពុំប្រព្រឹត្តអាក្រក់តបវិញ ទោះអ្នកនោះកែគំនិតអាក្រក់ក្តី មិនកែក្តី អ្នកប្រព្រឹត្តល្អពុំតបតពិតជាមានជ័យជំនះ ព្រោះពុំបានប្រព្រឹត្តអាក្រក់តបដែលជាហេតុនាំឱ្យមានទុក្ខទោសទៅមុខ។

ពាក្យថា គប្បីឈ្នះមនុស្សកំណាញ់ដោយការឱ្យ បានសេចក្តីថា មនុស្សកំណាញ់ គឺមនុស្សជាប់ជំពាក់នឹងទ្រព្យសម្បត្តិរបស់ខ្លួន

ខ្លាំង មិនចង់លះបង់ឱ្យដល់អ្នកដទៃ។ បើជនណាមួយឧស្សាហ៍ឱ្យវត្ថុផ្សេងៗដល់ជននោះ ថ្ងៃណាមួយជននោះនឹងរីករាយចិត្តហើយលះបង់នូវសេចក្តីកំណាញ់របស់ខ្លួន ឱ្យ នូវវត្ថុផ្សេងៗដល់ជននោះវិញ ដោយកើតគំនិតថា គេមានចិត្តល្អនឹងខ្លួនៗត្រូវតែមានចិត្តល្អនឹងគេវិញ។

ពាក្យថាគប្បីឈ្នះមនុស្ស និយាយពាក្យពុំពិតដោយពាក្យពិត មានន័យថា ជនណាម្នាក់តែងតែនិយាយពាក្យពុំពិតនៅចំពោះមុខអ្នកដែលនិយាយតែពាក្យពិត លុះការពិតបានលេចចេញឡើង អ្នកនិយាយការពុំពិតនោះ ត្រូវចាញ់ខ្លួនឯង ខ្មាសសំដីខ្លួនឯង ជាសំដីគ្មានតម្លៃ គេមិនជឿទុកចិត្ត ដូចពាក្យខ្មែរថា ពាក្យភូតចាញ់អាត្មា។ ពាក្យខ្មែរមួយទៀតថា សំដីជាឯក គឺសំដីជាលេខមួយ។ ពាក្យខ្មែរថា រនាបបាក់យករនាបជួស សំដីហួសគ្មានអ្វីជួសបានឡើយ។ មនុស្សគេយកសំដី ដំរីគេយកភ្លុក។ តាមព្រះពុទ្ធសាសនាពោលថា ដើម្បីដឹងមនុស្សល្អអាក្រក់ គេត្រូវពិនិត្យមើលសកម្មភាពការងារ មិនត្រូវស្តាប់ ជឿសំដីតែម្យ៉ាងឡើយ៕

## ៦. ព្រះពុទ្ធសាសនាប្រៀបមកវិទ្យាសាស្ត្រ

ព្រះពុទ្ធព្រះបរមគ្រូ ព្រះអង្គត្រាស់ដឹងនូវហេតុផលទូទៅ ឬហេតុផលសព្វគ្រប់ ដែលហៅថា សព្វញ្ញុតញ្ញាណ។ ហេតុផលមួយភាគដូចហេតុផលរបស់វិទ្យាសាស្ត្រ ហើយហេតុផលជាច្រើនទៀតវិទ្យាសាស្ត្រពុំមាន។ ព្រះពុទ្ធសំដែងអំពីហេតុផលតាមរូបធាតុផង និងនាមធាតុ គឺចិត្ត ចេតសិកផង។ ចំណែកវិទ្យាសាស្ត្រសំដែងជាពិសេស អំពីរូបធាតុ ។ ថ្ងៃមួយព្រះអង្គបានយាងធ្វើដំណើរជាមួយអានន្ទ បានឈប់នៅក្រោមម្លប់ដើមឈើមួយដើម ព្រះអង្គបានក្តាប់ស្លឹកឈើមួយក្តាប់ ហើយសួរព្រះអានន្ទជា ប្រស្នាថា ម្នាលអានន្ទ ស្លឹកឈើក្នុងព្រះហស្តតថាគត និងស្លឹកឈើដែលធ្លាក់នៅពាសពេញលើផែនដី តើស្លឹកឈើណាច្រើនជាង ព្រះអានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ស្លឹកឈើក្នុងព្រះហស្តព្រះអង្គមានចំនួនតិចណាស់ ចំណែកស្លឹកឈើដែលធ្លាក់នៅលើផែនដី មានចំនួនច្រើនណាស់ ពុំអាចរាប់ចំនួនបានឡើយ។ ពេលនោះព្រះពុទ្ធសំដែងថា ពិតមែនហើយអានន្ទធម៌ដែលតថាគតបានសំដែងប្រោសសត្វមានចំនួនតិចណាស់ ដូចស្លឹកឈើដែលនៅក្នុងព្រះហស្តតថាគត ចំណែក ធម៌ដែលតថាគតបានត្រាស់ដឹងហើយ មិនបានសំដែងប្រាប់សត្វមាន

ចំនួនច្រើនណាស់ ដូចស្លឹកឈើដែលនៅពាសពេញលើផែនដី ម្នាលអានន្ទ តថាគតសំដែងតែធម៌ណាដែលនាំទៅរកការរំដោះទុក្ខរបស់សត្វទាំងឡាយ ដូចតថាគតសំដែងអំពីអរិយសច្ច ៤ មានទុក្ខសច្ចជាដើម។ ព្រះពុទ្ធសំដែងថា វត្ថុទាំងអស់ក្នុងលោក ទាំងមានវិញ្ញាណទាំងគ្មានវិញ្ញាណ សុទ្ធតែកើតមកពីគ្រឿងផ្សំ ដែលបាលីហៅថា សង្ខារ (corps compose) អង់គ្លេសថា (component) ។ បានសេចក្តីថា វត្ថុធម្មជាតិមនុស្សសត្វទាំងអស់ កើតឡើងពីគ្រឿងផ្សំ ពុំមែនជាតួខ្លួនវាពិតទេ ប្រព្រឹត្តទៅជា អនិច្ចំ ទុក្ខំ និង អនត្តា កើតឡើងហើយតែងរលត់ទៅវិញជាធម្មតា។ ពាក្យព្រះពុទ្ធថា អ្វីទាំងអស់កើតឡើងពីគ្រឿងផ្សំដែលហៅថា សង្ខារ នេះចាត់ទុកជាមូលដ្ឋាននៃវិទ្យាសាស្រ្ត ព្រោះអ្នកប្រាជ្ញវិទ្យាសាស្រ្តផ្នែករូបវិទ្យាក្តី គីមីវិទ្យាក្តី រកឃើញថាវត្ថុធាតុទាំងអស់ កើតឡើងពីគ្រឿងផ្សំដោយធាតុយ៉ាងល្អិតដែលហៅថា បរមាណូ (atom) ដែលផ្តុំគ្នាច្រើនកើតជា កោសិកា (molecule) ហើយវត្ថុធាតុម្យ៉ាងកើតឡើងដោយខ្លួនវាដូចជាទឹក ដី ភ្លើង ខ្យល់ ព្រះអាទិត្យ ព្រះចន្ទជាដើម គ្មានអ្នកណាបង្កើតទេ គឺកើតឡើងតាមធម្មតារបស់លោកធាតុ។ វត្ថុធាតុម្យ៉ាងទៀត កើតឡើងពីបញ្ញារបស់មនុស្សយកវត្ថុផ្សេងៗមកផ្សំគ្នា ដើម្បីបង្កើតជាទីលំនៅ ប្រដាប់

ប្រជាប្រើប្រាស់ គ្រឿងបរិភោគជាដើម ដូចជាផ្ទះសម្បែង រថយន្ត អាកាសយាន ចំណីអាហារគ្រប់យ៉ាងជាដើម។ ត្រង់ផ្នែករូបធាតុនេះ ព្រះពុទ្ធសាសនា និងវិទ្យាសាស្ត្រមានហេតុផលស្របគ្នា។ នៅក្នុងបរមត្ថអភិធម្មរបស់ព្រះពុទ្ធសាសនាផ្នែករូបមាននិយាយអំពីអវិនិព្ភោគរូប ៨ គឺ បឋវី អាបោ តេជោ វាយោ គន្ធោ រសោ វណ្ណោ ឱជា តែងនៅជាមួយគ្នាពុំអាចបែងចែកឱ្យដាច់ពីគ្នាបានឡើយ។ ត្រង់នេះហើយ ដែលស្របនឹងវិទ្យាសាស្ត្រថា វត្ថុល្អិតដែលជាបរមាណូពុំអាចញែកឱ្យដាច់ពីគ្នា ដូចពុទ្ធសាសនាពោលដែរ។ ដោយព្រះពុទ្ធសាសនា និងវិទ្យាសាស្ត្រមានន័យស្របគ្នារវាងហេតុនិងផលនេះហើយ ដែលអាចនិយាយបានថា ទៅអនាគតទៀត បើអ្នកវិទ្យាសាស្ត្ររកឃើញការពិតនេះកាន់តែច្រើនឡើងនោះនឹងធ្វើឱ្យគេយល់ការពិតរបស់ព្រះពុទ្ធសាសនាកាន់តែជ្រៅជ្រះឡើងដែរ។ បានសេចក្ដីថា បើគេជឿហេតុផលរបស់វិទ្យាសាស្ត្រ ក៏ដូចជាគេជឿហេតុផលរបស់ព្រះពុទ្ធសាសនាដែរ។ ត្រង់នេះបញ្ជាក់ថា ពុទ្ធសាសនិកជនខ្មែរ មានវិចារណញ្ញាណ ដ៏ជ្រៅក្នុងការជ្រើសរើសជំនឿរបស់ខ្លួនចំពោះព្រះពុទ្ធសាសនាដែលជាសាសនាមាន ហេតុផលតាមលក្ខណៈវិទ្យាសាស្ត្រដែលខុសគ្នាតែត្រង់ វិទ្យាសាស្ត្រស្វែងរកសុខឱ្យមនុស្ស និងសង្គមមនុស្សជា

លោកិយសច្ចៈ ចំណែកព្រះពុទ្ធសាសនារកសុខឱ្យ មនុស្ស និងសង្គមមនុស្ស មិនត្រឹមតែលោកបច្ចុប្បន្ននេះទេ ថែមទាំងរកសុខឱ្យមនុស្សជាលោកុត្តរសច្ចៈ ឬនិព្វានសច្ចៈ រំលត់សេចក្ដីទុក្ខទាំងស្រុងតែម្ដង។

ភាពស្របគ្នារវាងព្រះពុទ្ធសាសនា និងវិទ្យាសាស្ត្រគឺ ជំនឿត្រូវតែស្ថិតនៅលើហេតុផល ហើយផលណាមួយកើតឡើងមកពីមានហេតុ។ ពុទ្ធសាសនានិយាយអំពីត្រៃលក្ខណ៍ធម៌ អនិច្ចំ ទុក្ខំ និងអនត្តា ដែលជាលក្ខណៈរបស់វត្ថុធាតុទាំងអស់ ទាំងមានវិញ្ញាណ និងគ្មានវិញ្ញាណ ចំណែកវិទ្យាសាស្ត្រនិយាយថា វត្ថុទាំងឡាយ តែងមានការផ្លាស់ប្ដូរតាមការពិសោធន៍ផ្នែករូបវិទ្យា និងគីមីវិទ្យា។ ពុទ្ធសាសនានិយាយថា ផលវិបាកដែលកើតចេញពីហេតុមួយហើយ ផលនោះអាចបង្កើតជាហេតុមួយតទៅទៀតដែល មានិយាយក្នុងវដ្ដៈ ៣ គឺ កិលេសវដ្ដៈ អវិជ្ជា តណ្ហា ឧបាទាន អាចកើតមានកម្មវដ្ដៈ ការសាងកម្ម ហើយកើតវិបាកវដ្ដៈ គឺផលរបស់កម្ម។ ចំណែកវិទ្យាសាស្ត្រនិយាយថា រុក្ខជាតិគ្រប់ប្រភេទដែលដុះលូតលាស់ ចេញជាដើម ផ្លែ ផ្កា មកពី (ពីជៈ) គឺពូជរបស់វាផ្សំនឹងការដាំលើដីដែលមានជីជាតិល្អផង។ ពុទ្ធសាសនានិយាយថា មនុស្ស សត្វ កើតពីធាតុទាំង ៤ គឺធាតុ ទឹក ដី ភ្លើង

ខ្យល់ ចំណែកវិទ្យាសាស្ត្រក៏ និយាយថា មនុស្សសត្វកើតពីគ្រឿងផ្សំដោយធាតុផ្សេងៗដែរ។ ត្រង់នេះ ព្រះពុទ្ធសាសនានិយាយលើសពីវិទ្យាសាស្ត្រ ត្រង់កំណើតរបស់មនុស្សត្រូវមានវិបាកវិញ្ញាណរបស់សត្វមកចាប់បដិសន្ធិផង។ ព្រះពុទ្ធសាសនានិយាយពិភពលោកមានសែនកោដិចក្រវាឡ ឬសែនកោដិលោកធាតុ ចំណែកវិទ្យាសាស្ត្រក៏និយាយដូចគ្នា តាមការឆ្លុះមើលក្នុងអវកាសថាមានលោកធាតុដទៃទៀតជាច្រើនរាប់មិនអស់ ដែល (កាឡាក់ស៊ី) galaxy ក្នុងសាកលចក្រវាឡ (universe) ។ ប៉ុន្តែវិទ្យាសាស្ត្រខុសពីពុទ្ធសាសនា ត្រង់មិនសូវគិតពីសីលធម៌ ដូចជាការបង្កើតគ្រឿងសាស្ត្រាវុធគ្រាប់បែកគ្រប់ផុន រហូតបង្កើតគ្រាប់បែកបរមាណូ ដើម្បីឱ្យមនុស្សយកទៅសម្លាប់គ្នា។ ចំណែកព្រះពុទ្ធសាសនាវិញ គ្រឿងប្រល័យមនុស្សទាំងនេះព្រះពុទ្ធបានហាម ថែមទាំងព្រះអង្គបានប្រកាសថា សេចក្តីសុខគ្រប់យ៉ាងកើតពីការស្ងប់ មិនធ្វើអំពើបាបគឺការមិនបៀតបៀនគ្នានេះឯង៕

## ៧. សិទ្ធិមនុស្សផ្នែកសិទ្ធិពលរដ្ឋ ប្រៀបមកព្រះពុទ្ធសាសនា

មាត្រា២១ ប្រការ១ នៃធម្មនុញ្ញសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានចែងថា បុគ្គលគ្រប់ រូបមានសិទ្ធិចូលរួម កាន់កាប់កិច្ចការគ្រប់គ្រងប្រទេសរបស់ខ្លួនដោយផ្ទាល់ខ្លួន ឬតាមរយៈអ្នកតំណាងទាំងឡាយដោយសេរី។ មាត្រានៃច្បាប់នេះមានន័យថាពលរដ្ឋម្នាក់ៗនៃប្រទេសមួយមានសិទ្ធិគិតគូរ អំពីវាសនាប្រទេសរបស់ខ្លួន ហើយមានសិទ្ធិចូលរួមគ្រប់កិច្ចការរបស់រដ្ឋដោយផ្ទាល់ខ្លួន ឬតាមរយៈអ្នកតំណាង។ បានសេចក្ដីថា ពលរដ្ឋមានសិទ្ធិប្រឡងប្រជែងចូលកាន់កិច្ចការរដ្ឋ ឬឈរឈ្មោះឱ្យគេជ្រើសរើសដោយសេរី និងមានសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងកិច្ចការរដ្ឋ។ មាត្រា២១ ប្រការ២ ចែងថា បុគ្គលគ្រប់រូបមានសិទ្ធិចូលកាន់មុខងារ ក្នុងតំណែងសាធារណៈនៃប្រទេសរបស់ខ្លួនដោយស្មើមុខ។ គឺពលរដ្ឋមួយរូបៗមានសិទ្ធិស្មើគ្នាក្នុងការចូលកាន់តំណែងក្នុងរដ្ឋទៅតាមសមត្ថភាព និងទៅតាមការបោះឆ្នោតដោយគ្មានលក្ខខណ្ឌ ដោយទ្រព្យសម្បត្តិដោយពូជអម្បូរណ៍កូនអ្នកធំអ្នកតូចឡើយ។ មាត្រាច្បាប់នេះ បើប្រៀបធៀបមកពុទ្ធសាសនាវិញ ព្រះពុទ្ធសំដែងថា មនុស្សគ្រប់រូបកើតមកពី

ធាតុ៤ដូចគ្នា តែដែលធ្វើឱ្យមនុស្សប្លែកគ្នានោះ គឺដោយសារអំពើ ឬកម្ម ឬការងារដែលគេបានធ្វើ។ បុគ្គលមានឋានៈបែបណាក៏ដោយបើគេប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ចាត់ទុកជាបុគ្គលថោកទាប។ បុគ្គលដែលប្រព្រឹត្តល្អដោយ កាយ វាចា ចិត្ត ចាត់ទុកជាបុគ្គលខ្ពង់ខ្ពស់ថ្លៃថ្នូរ។ ដូច្នេះ ទំនាប និង កំពស់របស់មនុស្សត្រូវស្ថិតនៅលើអំពើរបស់គេ ពុំមែនស្ថិតនៅលើទ្រព្យសម្បត្តិ យសស័ក្តិ ជាតិ ត្រកូលឡើយ។

មាត្រា២១ ប្រការ៣ នៃធម្មនុញ្ញសិទ្ធិមនុស្សចែងថា ឆន្ទៈប្រជាជនជាគ្រឹះនៃអំណាចសាធារណៈ។ ឆន្ទៈនេះត្រូវបញ្ចេញតាមរយៈការបោះឆ្នោតជាសាកលដោយត្រឹមត្រូវ និងសម្ងាត់ ឬតាមវិធីដូចគ្នា ដែលមានការធានារ៉ាប់រងសេរីភាពដល់ការបោះឆ្នោត។ មាត្រានៃច្បាប់នេះបញ្ជាក់ថា អំណាចគ្រប់យ៉ាងកើតចេញមកពីប្រជាពលរដ្ឋ ប្រជាពលរដ្ឋជាម្ចាស់នៃអំណាច អំណាចកើតចេញមកពីឆន្ទៈរបស់ប្រជាពលរដ្ឋ តាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ ដោយគ្មានការបន្លំ។ ពាក្យថា ជាសាកលបានន័យថាជាទូទៅ។ ពាក្យថាសម្ងាត់បានន័យថា ពុំឱ្យជនណាម្នាក់ដឹងថាបោះឆ្នោតឱ្យអ្នកណា។ មាត្រាដែលថា តាមវិធីដូចគ្នាដែលមានការធានារ៉ាប់រងសេរីភាពដល់ការបោះឆ្នោត បានន័យថា ឱ្យមានអ្នក

ធានាការពារកុំឱ្យជនណា ឬក្រុមណាគម្រាមកំហែងបង្ខិតបង្ខំសូក ប៉ាន់ឱ្យបោះឆ្នោតឱ្យគណបក្សណាមួយ ដែលពុំស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ។ នេះជាអត្ថន័យនៃរបបប្រជាធិបតេយ្យដែលមានប្រជាពលរដ្ឋជាធំ ជាអធិបតី ជាម្ចាស់អំណាច។ ប្រៀបមកពុទ្ធសាសនា ក្នុងពេលដែលព្រះសង្ឃកើតឡើងមានចំនួនច្រើនហើយ ព្រះសម្មាសម្ពុទ្ធបានអនុញ្ញាតឱ្យព្រះសង្ឃ សម្រេចកិច្ចការគ្រប់យ៉ាងក្នុងព្រះពុទ្ធសាសនា ដោយការប្រជុំសម្រេចពីប្រជុំសង្ឃតាមទីកន្លែងនីមួយៗ។ សមាជិកព្រះសង្ឃដែលមកប្រជុំមានចំនួនច្រើនតិច យោលទៅតាមទំហំការងារដែលសំខាន់ល្មម និងសំខាន់ខ្លាំងដែលហៅថា សង្ឃកម្ម។ ការខ្លះដែលជា កាតព្វកិច្ចរបស់ព្រះសង្ឃដែលត្រូវតែធ្វើដូចឧបោសថកម្ម គ្រាន់តែសូត្រប្រកាសប្រាប់ឱ្យសង្ឃដឹងហៅថាញត្តិ ទុកជាបានការគ្មានការពិភាក្សាគ្នាទេ។ ការខ្លះសំខាន់ល្មម ដូចជាកឋិនកម្ម ត្រូវប្រកាសប្រាប់សង្ឃហៅថាញត្តិ ហើយត្រូវសួរឱ្យសម្រេចតែម្តង ហៅថា ញត្តិទុតិយកម្មវាចា ដើម្បីឱ្យស្រុះស្រួលគ្នាប្រគល់សំពត់កឋិន ឱ្យអង្គណាមួយក្រាលគ្រងកឋិន។ បើការងារដែលសំខាន់ខ្លាំងដូចជាឧបសម្បទាកម្ម គឺការសម្រេចឱ្យបួសជាភិក្ខុ ត្រូវប្រកាសម្តងដែលហៅថាញត្តិ ហើយសួរយោបល់ព្រះសង្ឃរហូតដល់ ៣ដង

តើសម្រេចឱ្យបួសឬមិនឱ្យបួស ហៅថា ចតុត្ថកម្មវាចា ព្រោះការអនុញ្ញាតឱ្យមនុស្សម្នាក់ៗបួស ត្រូវពិនិត្យពិច័យពិចារណាឱ្យបានម៉ត់ចត់ កុំឱ្យខូចតម្លៃព្រះពុទ្ធសាសនា ដោយសារតែឱ្យមនុស្សមិនល្អបួស។ ការចាត់ភិក្ខុអង្គណាមួយឱ្យបំពេញកិច្ចការរបស់សង្ឃ ដូចជាចាត់ឱ្យទៅឱ្យឱវាទដល់ភិក្ខុនី ចាត់ឱ្យទទួលភារៈបម្រើសង្ឃជាដើម តែងតែចាត់ទៅតាមសមត្ថភាព និងគុណធម៌របស់ភិក្ខុនោះ។ ក្រឡេកមើលរបបកុម្មុយនីស្ត ជាពិសេសកុម្មុយនីស្តខ្មែរក្រហម ប្រជាធិបតេយ្យគ្មានទេ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ក៏គ្មានសោះឡើយ ព្រោះរបបនេះមានគណបក្សតែមួយ គេឱ្យប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ តំណាងប្រជាជន គឺជាបេក្ខជនដែលមជ្ឈិមបក្សតែងតាំងរួចហើយ។ ការបោះឆ្នោតនេះគ្មានន័យអ្វីឡើយ គ្រាន់តែជាសកម្មភាពខាងក្រៅបន្លំភ្នែកអន្តរជាតិឱ្យមើលឃើញថារបបនេះ គោរពសិទ្ធិប្រជាពលរដ្ឋ។ ធម្មនុញ្ញសហប្រជាជាតិដែលចែងថា ឆន្ទៈប្រជាជនជាគ្រឹះនៃអំណាចសាធារណៈនោះ ពុំមានក្នុងរបបនេះឡើយ ព្រោះអំណាចទាំងអស់ស្ថិតនៅលើមជ្ឈិមបក្ស ដែលមានគ្នាតែពីរបីនាក់ប៉ុណ្ណោះ។ ចំណែកប្រទេសកម្ពុជាបច្ចុប្បន្ន ក្នុងរដ្ឋធម្មនុញ្ញចែងថា កាន់របបប្រជាធិបតេយ្យសេរីពហុបក្ស បើអនុវត្តឱ្យបាន

ត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនេះ ជាការប្រពៃណាស់ ជាពិសេសការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របង្កើតរដ្ឋាភិបាល។ ការអនុវត្តតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងតាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន អាចឱ្យខ្មែរជៀសវាង សង្គ្រាមក្នុងស្រុកជាថ្មីទៀត ហើយអាចឱ្យខ្មែររួបរួមគ្នាដោះស្រាយបញ្ហាជាតិឆ្ពោះទៅរកសន្តិភាព និងវឌ្ឍនភាពទប់ទល់បរទេសឈ្លានពានពីខាងក្រៅ៕

## ៨. ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃ

ពុទ្ធភាសិតថា ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃនេះ មានជម្រៅណាស់គឺឈ្នះសេចក្ដីអាក្រក់ ដោយការពុំធ្វើអំពើអាក្រក់ អប់រំចិត្តឱ្យបានស្អាតបរិសុទ្ធ។ ចិត្តបរិសុទ្ធ គឺចិត្តស្ងប់ពុំធ្វើអំពើបាបគ្រប់យ៉ាង មានការបៀតបៀនអ្នកដទៃជាដើម ស្រប នឹងពុទ្ធភាសិតមួយទៀតថា ការចង់បានសុខខ្លួនឯងទៅបៀតបៀនអ្នកដទៃពុំបានសុខឡើយ។ អ្នកប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្ត ឈ្មោះថាជាអ្នកឈ្នះ អ្នកប្រព្រឹត្តទុច្ចរិតឈ្មោះថាជាអ្នកចាញ់ ព្រោះអំពើទុច្ចរិតនេះនឹងផ្ដល់សេចក្ដីទុក្ខមកដល់ខ្លួនវិញ។ អ្នកខ្លះយល់ថា បើអប់រំចិត្តឱ្យល្អបរិសុទ្ធទុកជាអ្នកទន់ខ្សោយ ជាអ្នកចាញ់គេ តាមពិតវិញបើចិត្តបរិសុទ្ធរមែងមានចិត្តសុខស្ងប់ហើយ ពុំធ្វើកម្មអាក្រក់ដែលឱ្យផលជាទុក្ខឡើយ។ ផ្ទុយមកវិញ បើចិត្តពុំបរិសុទ្ធរមែងធ្វើអំពីបាប ហើយផលនៃអំពើបាបនោះតែងផ្ដល់ផលជាទុក្ខដល់ខ្លួន ជាពិសេស បើប្រព្រឹត្តអាក្រក់ទៅលើជនណាម្នាក់ មុខជាមានប្រតិកម្មតបតវិញក្នុងពេលភ្លាម ឬក្នុងពេលណាមួយដែលឱកាសហុចឱ្យ ដោយផលនៃអំពើបាបដែលខ្លួនប្រព្រឹត្តទៅលើគេ។ ដូច្នេះជំនះខ្លួនឯងជាជំនះប្រសើ ព្រោះពុំមានពៀរវេរាជាមួយអ្នកដទៃ ចំណែកជំនះក្រៅពីនោះ ដូចជាជំនះ

ដោយលេងល្បែងភ្នាល់ផ្សេងៗ ជំនះដោយការវិវាទធម្មតាក្ដី ថ្នាក់ជាតិក្ដី បើជំនះនោះប្រកបដោយការឈ្លានពានផង ជំនះនោះ នឹងត្រឡប់ចាញ់វិញ។

ជំនះខ្លួនឯងដោយការពុំធ្វើអំពើបាបនះ ពុំមែនជម្រុញមិនឱ្យការពារទឹកដី ការពារឯករាជ្យរបស់ខ្លួនឡើយ ផ្ទុយទៅវិញ ភាពនៃចិត្តបរិសុទ្ធនេះនាំឱ្យមានវិចារណញ្ញាណដ៏ខ្ពស់ ជម្រុញឱ្យរក្សាការពារ អត្តសញ្ញាណជាតិ និងកម្មសិទ្ធិគ្រប់យ៉ាងរបស់ជាតិ មានទឹកដីជាដើម ដោយការប្រុងប្រយ័ត្ន។ តាមព្រឹត្តិការណ៍សាកលលោករហូតមកដល់ពេលនេះ អ្នកប្រព្រឹត្តអាក្រក់រំលោភសិទ្ធិមនុស្សត្រូវបានទទួលទោស ទណ្ឌកម្មនៅទីបំផុត។ ហេតុដែលនាំឱ្យមនុស្សសាងអាក្រក់ មកអំពីគំនិតយល់ខុសថា អំពើរបស់ខ្លួននោះអាចផ្ដល់សេចក្ដីសុខឱ្យដល់ខ្លួន។ នេះជាការយល់ផ្ទុយអំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្រះអង្គសំដែងថាអំពើអាក្រក់តែងផ្ដល់ផលជាទុក្ខ ពុំមែនផ្ដល់ផលជាសុខឡើយ។ មួយទៀត ការកើតវិវាទនឹងគ្នាមកអំពីការយល់ផ្ទុយគ្នារហូតបង្កើតអំពើហិង្សា ដើម្បីការពារគំនិតខ្លួនរហូតរកមធ្យោបាយធ្វើឱ្យគេវិនាសទៀតផង។ តាមព្រះពុទ្ធសាសនា ក៏ដូចគ្នានឹងរបបប្រជាធិបតេយ្យ ការបញ្ចេញយោបល់ស្របក្ដី ផ្ទុយពីមតិខ្លួនក្ដី

ត្រូវតែគោរពសិទ្ធិបញ្ចេញយោបល់ទាំងនោះ។ មុននឹងឈ្នះអ្នកដទៃ មនុស្សត្រូវឈ្នះខ្លួនឯងជាមុន ឈ្នះខ្លួនឯងគឺការពុំធ្វើអំពើបាប ជាពិសេសពុំបៀតបៀនអ្នកដទៃ។ ការមិនបៀតបៀននេះហើយ ជាស្នេហ៍មុខនាំឱ្យបន្ថយសត្រូវ ចម្រើនមិត្ត សម្បូណ៌មិត្តរាប់អានគ្នាដោយសេចក្ដីល្អរបស់ខ្លួន។ ជនសប្បុរសដែលតែងតែប្រព្រឹត្តធ្វើអំពើល្អនេះ មិនថាតែមនុស្សទេដែលយកជាមិត្ត សូម្បីសត្វតិរច្ឆានក៏ចូលមកជិតយកជាមិត្តដែរ គឺបើមនុស្សមិនបៀតបៀនវា វាមិនមានការភិតភ័យ តែងចូលមកជិតសំដែង ការស្រឡាញ់រាប់អាន។ បានសេចក្ដីថា ជនសប្បុរសស្ងប់នូវអំពើបាប លោករស់នៅទីណា តែងតែធ្វើឱ្យជនដែលរស់នៅទីនោះបានសេចក្ដីសុខ ហើយតែងតែបង្ហាញនូវមាគ៌ាដែលនាំឱ្យជននោះបានសេចក្ដីសុខថែមទៀត។

ចំពោះព្រះពុទ្ធជាម្ចាស់ដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធនោះ គឺដោយព្រះអង្គឈ្នះខ្លួនព្រះអង្គឯង។ តើព្រះពុទ្ធឈ្នះនូវអ្វី គឺឈ្នះនូវមារមានកិលេសមារជាដើម។ យោងតាមពុទ្ធប្រវត្តិ ព្រះសិទ្ធត្ថពោធិសត្វ មុននឹងបានត្រាស់ជាព្រះពុទ្ធ ព្រះអង្គបានផ្ចាញ់មារពីរប្រភេទ គឺមារមួយប្រភេទប្រើសង្គ្រាមក្ដៅ គឺមារាធិរាជព្រមទាំងបរិវារជាច្រើនពាន់ មានអាវុធគ្រប់ដៃចូលប្រយុទ្ធវាយប្រហារចំពោះព្រះបរមពោធិសត្វដែលគង់ក្រោមដើមពោធិព្រឹក្ស ដោយ

ព្រះទ័យស្ងប់ក្នុងសមាធិ។ ព្រះអង្គផ្សាយធម៌តបមារវិញ ដោយធម៌មេត្តានិងបារមីទាំង១០ដែលព្រះអង្គបានកសាង មារក៏ត្រូវបរាជ័យ។ មារប្រភេទទីពីរ គឺមារប្រើសង្គ្រាមត្រជាក់ គឺមារាធិរាជប្រើបុត្រីទាំងបីរបស់ខ្លួន ដែលមានរូបរាងកាយស្អាតបាតមកប្រលោមលួងលោមព្រះពោធិសត្វដោយផ្លូវកាមគុណ ពេលនោះមារត្រូវបរាជ័យទៀតដោយព្រះពោធិសត្វមានស្មារតីដ៏រឹងមាំក្នុងផ្លូវសមថវិបស្សនា។ មារប្រភេទក្តៅបានដល់ទោសៈ មារប្រភេទត្រជាក់បានដល់លោភៈ ឬ រាគៈ។ បន្ទាប់ពីមារត្រូវបរាជ័យហើយ ព្រះពោធិសត្វព្រះសិទ្ធត្ថក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ឈ្មោះថាព្រះអង្គឈ្នះខ្លួនឯងហើយ។

យោងតាមពុទ្ធភាសិតថា ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃបានជាមេរៀនសម្រាប់សង្គមកម្ពុជា ដោយខ្មែរគ្រប់ឋានៈគប្បីរួបរួមគ្នារក្សាការពារជាតិ ការពារទឹកដី កាពារឯករាជ្យរបស់ខ្លួនឱ្យបានគង់វង្សក្នុងស្មារតីជាតិឱ្យបានរឹងមាំ ជាពិសេសអ្នកកាន់អំណាចខ្មែរបច្ចុប្បន្នត្រូវធ្វើខ្លួន ឱ្យឈ្នះខ្លួនឯង ពោលគឺកុំសាងអាក្រក់ធ្វើឱ្យពលរដ្ឋខ្លួនមានទុក្ខក្តៅក្រហាយ បញ្ហាដីធ្លីត្រូវដោះស្រាយឱ្យមានសមធម៌ ត្រូវគោរពការបញ្ចេញមតិរបស់ពលរដ្ឋដោយសេរីដូចការធ្វើកូដកម្ម បាតុកម្មជាដើម ដោយមិនត្រូវ

បង្ក្រាប តែត្រូវរក្សាសន្តិសុខឱ្យពលរដ្ឋក្នុងការធ្វើកូដកម្ម បាតុកម្ម ដោយសន្តិវិធីស្របតាមច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន៕

## ៩. ប្រវត្តិចិត្តរបស់មនុស្ស

ចិត្តប្រែថា ការត្រិះរិះ ឬការសន្សំនូវអារម្មណ៍ ជាធម្មជាតគ្មានរូបរាង សណ្ឋាន ទ្រង់ទ្រាយអ្វីទេ ជានាមធម៌ ប៉ុន្តែវាមានភាពពិតជាវិជ្ជមាន ដែលមនុស្សម្នាក់ៗអាចដឹងបានដោយខ្លួនឯង។ ចិត្តគ្មានប្រក្រតីពីកំណើតដើមរបស់វាទេ ប៉ុន្តែមានចិត្តដោយសារអាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ប៉ះនឹងអាយតនៈខាងក្រៅ ៦ គឺ រូប សម្លេង ក្លិន រស សម្ផស្ស និង ធម្មា (អារម្មណ៍ដែលចិត្តតោង) ដែលហៅថាផស្សាយតនៈ ហើយប្រព្រឹត្តទៅជាខណៈចិត្តជាវិធីចិត្ត ទើបកើតជាចិត្តជាវិញ្ញាណឡើយ។ ព្រះសម្ពុទ្ធបានសំដែងនៅក្នុងបដិច្ចសមុប្បាទធម៌ ដែលប្រែថា ធម៌កើតឡើងព្រមដោយអាស្រ័យហេតុ ដែលមានហេតុផលទំនាក់ទំនងគ្នា១២យ៉ាង គឺកាលណាមានអវិជ្ជា នាំឱ្យមានសង្ខារ សង្ខារនាំឱ្យមានវិញ្ញាណ វិញ្ញាណនាំឱ្យមាននាមនិងរូប នាមនិងរូបនាំឱ្យមានអាយតនៈ៦ អាចយនៈ៦ នាំឱ្យមានផស្សៈ ផស្សៈនាំឱ្យមានវេទនា វេទនានាំឱ្យមានតណ្ហា តណ្ហានាំឱ្យមានឧបាទាន ឧបាទាននាំឱ្យមានភព ភពនាំឱ្យមានជាតិ ជាតិនាំឱ្យមានជរានិងមរណៈ។ ដូច្នេះយើងឃើញថា ហេតុផលដែលកើតឡើងជាបន្តគ្នានេះ មានអវិជ្ជា ការពុំដឹង

នូវអរិយសច្ច៤ មានទុក្ខសច្ចជាដើមជាមេហេតុ។ កាលណាអវិជ្ជារលត់ ហេតុផលបន្តក៏ត្រូវរលត់ដែរ។ នៅក្នុងហេតុផលនេះមានពោលអំពីផស្សៈ នាំឱ្យកើតវេទនា ពុំឃើញពោលអំពីផស្សៈនាំឱ្យកើតវិញ្ញាណទេឡើយ ប៉ុន្តែអ្នកសិក្សាគប្បីយល់ នូវផស្សៈពិតជានាំឱ្យកើតវិញ្ញាណ មុននឹងកើតវេទនា តែក្នុងទំនាក់ទំនងនេះ លោកពុំពោលទេឡើយ។ ផស្សៈការប៉ះគ្នា រវាងអាយតនៈខាងក្នុងនិងខាងក្រៅទើបកើតវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ទើបកើតចេតសិកធម៌មានវេទនាចេតសិកជាដើម។ ចំណែកពួករុក្ខជាតិពុំមានអាយតនៈទើបពុំអាចបង្កើតជា វិញ្ញាណជាចិត្តបាន។ ក្នុងបញ្ចទ្វារមានចក្ខុទ្វារជាដើម មានខណៈចិត្ត ១៧ និងវិថីចិត្ត៧។ ខណៈចិត្ត ១៧នោះគឺ ១- ភវង្គៈ កាត់ជាពីរបទ គឺភវៈ និង អង្គៈ។ អង្គៈប្រែថាប្រដាប់ ភវៈប្រែថា ចេតនា រួមពាក្យទាំងពីរប្រែថា ប្រដាប់សម្រាប់បង្កើតចេតនា។ បានសេចក្តីថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មានសរសៃប្រសាទនៅក្នុងនោះ អាចបង្កើតវិញ្ញាណបង្កើតចិត្ត បើកាលណាមានអាយតនៈទាំង៦ ខាងក្រៅមកប៉ះ។ បើគ្មានអាយតនៈខាងក្រៅណាមួយមកប៉ះទេ វានៅជាភវង្គៈធម្មតា ពុំទាន់កើតចិត្តទេ។ ដូចជាប្រដាប់ថតរូប បើគេពុំទាន់យកទៅថតទេ វានៅជាប្រដាប់ធម្មតា យ៉ាងណាមិញ ប្រដាប់ថតរូប

ដូចជា ភវង្គ រូបខាងក្រៅដូចជាអាយតនៈខាងក្រៅ។ ២- ភវង្គចលនៈ ប្រែថា ញ័រ ភវង្គៈនេះពេលអារម្មណ៍មកប៉ះ។ ៣- ភវង្គុប្បច្ឆេទ ប្រែថា ដាច់ខ្សែភវង្គ គឺខណៈនេះចេញផុតពីភវង្គហើយ។ ៤- បញ្ចទ្វារាវជ្ជនៈ ប្រែថា ការនឹករកអារម្មណ៍ក្នុងទ្វារទាំង ៥ មានចក្ខុទ្វារជាដើម។ ៥- បញ្ចវិញ្ញាណ ប្រែថា វិញ្ញាណ៥ សេចក្តីថា ខណៈចិត្តទី ៥ នេះ កើតវិញ្ញាណការដឹងហើយ។ ៦- សម្បដិច្ឆន្នៈ ការទទួលអារម្មណ៍នោះ។ ៧- សន្តីរណៈ ការពិចារណានូវអារម្មណ៍នោះ។ ៨- វោដ្ឋវនៈ កត់ត្រានូវអារម្មណ៍នោះ ត្រង់វោដ្ឋវនៈនេះជាតួសញ្ញាចាំបាននូវអារម្មណ៍ ដែលបានប៉ះនោះ។ បើខណៈចិត្តកើតឡើងតែត្រឹមនេះ មិនកើតបន្តទៀតទេ ចិត្តធ្លាក់កាន់ភវង្គវិញ លោកហៅថា អហេតុកចិត្ត ប្រែថាចិត្តគ្មានហេតុ។ ៩- ជវនៈ ប្រែថាចិត្តស្ទុះទៅ គឺចិត្តត្រេកអរ ឬប្រទូស្តចំពោះអារម្មណ៍នោះ។ ត្រង់ជវនៈនេះ ហើយចាត់ជាសហេតុកចិត្ត ប្រែថា ចិត្តប្រកបដោយហេតុ។ ហេតុនេះមាន ៦ គឺ កុសល ៣ បានដល់ អលោភោ អទោសោ អមោហោ និងអកុសល ៣ គឺលោភោ ទោសោ មោហោ។ ជវនៈកើតឡើង ៧ ខណៈក៏រលត់ទៅ ហើយខណៈចិត្តកើតឡើងត្រឹមជវនៈនេះ ហើយចាត់ជាបុណ្យជាបាប។ ១០- តទាលម្ពណៈ ប្រែថា តោងនូវអារម្មណ៍នោះ។ បានសេចក្តីថា បន្ទាប់ពីជវនៈកន្លងផុតទៅ

ចិត្តនៅតោងអារម្មណ៍នោះ ២ ខណៈទើបរលត់ទៅ។ ខណៈចិត្ត រាប់ពី ភវង្គៈ ដល់តទាលម្ពណៈ ត្រង់ជវនៈ មាន ៧ តទាលម្ពណៈ មាន ២ រួមជា ១៧ ចំណែកវិថីចិត្ត រាប់ពីបញ្ចទ្វារាវជ្ជនៈដល់ តទាលម្ពណៈ មាន ៧។ ផ្នែកមនោទ្វារាវជ្ជនៈវិញ មានវិថីចិត្តតែ ៣ គឺ មនោទ្វារាវជ្ជនៈ ជវនៈ និងតទាលម្ពណៈ ហើយខណៈចិត្តមាន ១០ គឺ មនោទ្វារាវជ្ជនៈ១ ជវនៈ ៧ និងតទាលម្ពណៈ២។

តាមការរៀបរាប់មកនេះបញ្ជាក់ថា ចិត្តវិញ្ញាណពុំមានទេ បើពុំមានផស្សៈ ការប៉ះរវាងអាយតនៈខាងក្នុង៦ និងខាងក្រៅ៦។ ឧទាហរណ៍ ការកើតវិញ្ញាណតាមភ្នែក គឺចក្ខុធាតុ ប៉ះនឹងរូបធាតុ កើតចក្ខុវិញ្ញាណធាតុ មនោធាតុប៉ះនឹងធម្មធាតុ (អារម្មណ៍តាម មនោទ្វារ) កើតមនោវិញ្ញាណធាតុ។ នេះជាការផ្សំគ្នារវាងរូបធម៌ទើប កើតនាមធម៌។ ចិត្តវិញ្ញាណជា អនត្តា ព្រោះកើតរលត់គ្រប់ខណៈ ហៅថា ខណិកមរណៈ ពុំមានខ្លួននេះហើយដែលព្រះពុទ្ធបដិសេធ សាសនាព្រាហ្មណ៍ដែលថា រូបស្លាប់ទៅ វិញ្ញាណដែលសាសនា នេះហៅថាអាត្ម័ន ឬអត្តា មិនស្លាប់ឡើយ៕

## ១០. អត្តា ហិ អត្តនោ នាថោ

ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួនពុទ្ធភាសិតថា ខ្លួនជាតីពឹងរបស់ខ្លួន គឺព្រះពុទ្ធពុំទទួលស្គាល់ថា មានអត្តា ដូចជាសាសនាព្រាហ្មណ៍ដែលយល់ថា នៅក្នុងខ្លួនមនុស្សសត្វមានអត្តា គឺខ្លួន ឬព្រលឹងវិញ្ញាណពុំចេះរលត់នោះឡើយ។ ព្រះអង្គមានញាណឃើញតាមសេចក្តីពិតថា ខ្លួនមនុស្សសត្វដែលប្រកបដោយខន្ធ ៥ មានរូបខន្ធ ជាដើមនេះ ជាអនត្តា ពុំមែនខ្លួន ព្រោះជាសង្ខារប្រព្រឹត្តទៅដោយខ្លួនវា តាមច្បាប់ធម្មជាតិមិនស្តាប់បង្គាប់។ ចំណែក អត្តាក្នុងព្រះពុទ្ធភាសិតនេះ សំដៅយកខ្លួនដែលផ្សេងពីអ្នកដទៃហើយសកម្មភាពល្អគ្រប់យ៉ាងត្រូវធ្វើដោយខ្លួនឯង ដូចពុទ្ធភាសិតមួយបទទៀតពោលថា សេចក្តីបរិសុទ្ធក្តី ពុំបរិសុទ្ធក្តី ត្រូវកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចញុំាងអ្នកដទៃឱ្យបរិសុទ្ធនិងមិនបរិសុទ្ធបានឡើយ។ ពាក្យថាខ្លួនជាទីពឹងរបស់ខ្លួននេះដកចេញពីពុទ្ធភាសិតទាំងមូលថា ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន អ្នកដទៃនឹងជាទីពឹងដូចម្តេចបាន បើបុគ្គលមានខ្លួនទុន្មានល្អហើយ រមែងបាននូវទីពឹងដែលគេបានដោយកម្រ។ ត្រង់នេះមានន័យជ្រៅថា អ្នកដែលមានខ្លួនទូន្មានរហូតបានសម្រេចជាព្រះអរហន្ត ជាថ្នាក់ខ្ពស់របស់ព្រះពុទ្ធសាសនា ក៏ដោយសារការ

ប្រតិបត្តិតាមធម៌ គឺសីល សមាធិ បញ្ញា ដោយខ្លួនឯង។ ពុទ្ធបរិស័ទតែងសូត្រថា យកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរលឹកស្មើដោយជីវិតនោះ មានន័យថា ជឿការត្រាស់ដឹងរបស់ព្រះអង្គ ជឿព្រះធម៌ជាធម៌ចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវតាមមគ្គ ប្រកបដោយអង្គ៨ ។ បន្ទាប់ពីមានជំនឿដូច្នេះហើយ ក៏ខំប្រតិបត្តិតាមព្រះធម៌ដែលព្រះអង្គសំដែងប្រាប់ ពុំមែនពឹងព្រះពុទ្ធឱ្យព្រះអង្គជួយ ឱ្យសម្រេចមគ្គផលថ្នាក់ណាមួយឡើយ ព្រះអង្គគ្រាន់តែបង្ហាញធម៌ប្រតិបត្តិប៉ុណ្ណោះ បើចង់បានសម្រេចមគ្គផលថ្នាក់ណាមួយ ត្រូវប្រតិបត្តិដោយខ្លួនឯង។ មួយទៀត ដូចគ្រូបង្រៀន និងសាស្ត្រាចារ្យមានភារកិច្ចត្រឹមតែពន្យល់ណែនាំសិស្ស និងនិស្សិតតាមមុខវិជ្ជាបង្រៀន ត្រូវសិស្ស និងនិស្សិតខំប្រឹងប្រែងស្តាប់លោកពន្យល់ និងធ្វើកិច្ចការដែលលោកដាក់ឱ្យ ទើបអ្នកសិក្សាមាន ការចេះដឹង ពុំមែនគ្រូជួយឱ្យចេះដោយសិស្សពុំបានប្រឹងប្រែងសិក្សារៀនសូត្រនោះឡើយ។ ពិតមែនតែ មនុស្សក្នុងលោករស់នៅតែងតែពឹងពាក់គ្នាទៅវិញទៅមក ដូចម្តាយឪពុក កូនចៅ ប្តីប្រពន្ធ គ្រូ និងសិស្ស អ្នកដឹកនាំនិងប្រជាពលរដ្ឋ ព្រះសង្ឃ និងគ្រហស្ថ ប្រទេសនីមួយៗ និងអង្គការសហប្រជាជាតិជាដើម តែងពឹងពាក់គ្នា តែងជួយឧបត្ថម្ភគ្នា ប៉ុន្តែ

ជាការជួយម្តងម្កាល ពុំអាចជួយជានិច្ចទ្បើយ ជាការជួយខាងក្រៅ ហើយអ្នកដែលគេអាចជួយ លុះត្រាតែមានលក្ខណៈគួរគេជួយ ឯការជួយនោះគ្រាន់តែជាការជួយឧបត្ថម្ភប៉ុណ្ណោះ ត្រូវតែខ្លួនឯងជួយដោយខ្លួនឯង។ សុភាសិតរបស់ពួកបស្ចិមប្រទេសក៏មានិយាយថា ដើម្បីឱ្យទេវតាជួយអ្នក អ្នកត្រូវជួយខ្លួនអ្នកជាមុនសិន។

ពាហិរសាសនា គឺសាសនាខាងក្រៅពីព្រះពុទ្ធសាសនា និយាយថា ព្រះអាទិទេពមានអំណាចឱ្យសុខឱ្យទុក្ខ ឱ្យទ្បើងស្ថានសួគ៌ ឱ្យចុះនរក ដល់មនុស្សសត្វ។ បើមនុស្សសត្វជឿព្រះអង្គ ធ្វើឱ្យព្រះអង្គ សព្វព្រះទ័យ ព្រះអង្គឱ្យកើតក្នុងស្ថានសួគ៌ បើមិនជឿព្រះអង្គ ធ្វើឱ្យព្រះអង្គខ្ញាល់ ព្រះអង្គនឹងឱ្យធ្លាក់នរក។ សុខទុក្ខ ចម្រើន វិនាស នរក សួគ៌ កើតចេញពីព្រះអាទិទេព ពុំមែនកើតទ្បើងពីអំពើល្អអាក្រក់ របស់មនុស្សសត្វកសាងដោយខ្លួនឯងខ្លួនទីពឹងខ្លួន ដូចព្រះពុទ្ធសាសនាពោលទ្បើយ។ ទស្សនៈរបស់ពាហិរសាសនានេះ ពុំមែនភស្តុតាងបញ្ជាក់ជាការពិតទ្បើយ ចំណែកព្រះពុទ្ធសាសនាវិញ ដូចបានពោលមកហើយ អ្វីទាំងអស់កើតពីកម្មផល ឬហេតុផលតាមសភាពខ្លួនវា មានលក្ខណៈជាសាកលតាមច្បាប់ធម្មជាតិ ដែលគេអាចពិសោធឃើញការពិតបានក្នុងជីវិតបច្ចុប្បន្ន។ ក្រុមអ្នកស្រាវជ្រាវវិទ្យា

សាស្ត្របានទទួលស្គាល់តម្លៃរបស់ព្រះពុទ្ធសាសនាថា មានហេតុផលពិត ស្របតាមលក្ខណៈវិទ្យាសាស្ត្រ ដែលខ្លួនបានពិសោធឃើញ ដូចមនុស្សឈឺ កើតឡើងពីហេតុគឺមេរោគតាមប្រភេទរបស់ជំងឺជាដើម។ ដរាបណាវិទ្យាសាស្ត្រចេះតែលូតលាស់ ដរាបនោះព្រះពុទ្ធសាសនា ចេះតែបង្ហាញការពិតកាន់តែច្បាស់លាស់ឡើង។ គេសង្កេតឃើញថា ចំនួនអ្នកកាន់ពាហិរសាសនានៅបស្ចិមប្រទេស គឺនៅលោកខាងលិច ដូចជាសហរដ្ឋអាមេរិក កាណាដា បារាំងជាដើម បានត្រូវថយចុះ ហើយចំនួនអ្នកកាន់ព្រះពុទ្ធសាសនាកាន់តែចម្រើនឡើង។ ដូច្នេះហើយបានជាបេសកជនរបស់ពាហិរសាសនា បានងាកទៅបញ្ចុះបញ្ចូលអូសទាញប្រជាជននៅប្រទេសអាស៊ីដែលកំពុងមានវិបត្តិ ដូចជាប្រទេសកម្ពុជាជាដើមឱ្យជឿសាសនារបស់ខ្លួន ព្រោះពុំអាចផ្សាយនៅក្នុងប្រទេសលោកខាងលិចឱ្យគេជឿបានទៀតឡើយ។ សម័យបារាំងបានធ្វើអានានិគមនិយមលើប្រទេសកម្ពុជា បារាំងគ្រីក្បាល ដោយពោលថាខ្មែរក្បាលរឹងណាស់ មិនងាយអូសទាញឱ្យជឿសាសនាដទៃទៀត ក្រៅពីព្រះពុទ្ធសាសនាឡើយ៕

## ១១. ព្រះពុទ្ធជាសង្គមវិទូ

បន្ទាប់ពីព្រះពុទ្ធត្រាស់ដឹង មុននឹងយាងទៅសំដែងធម៌ ព្រះអង្គពិចារណានូវបុគ្គលបីពួក ដែលគួរឱ្យព្រះអង្គសំដែងធម៌មុនគេ ព្រោះថា បុគ្គលបីពួកដែលព្រះអង្គបំរុងទៅប្រោសនេះ បើគ្មានធម៌ក្នុងខ្លួនទេ នឹងនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម។ បុគ្គលបីនោះគឺ ពួកបញ្ញវន្ត អ្នកមានចំណេះចេះដឹង ពួកឥស្សរជន អ្នកមានអំណាចបុណ្យស័ក្តិ និងអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។

តាមរយៈពុទ្ធប្រវត្តិ ព្រះអង្គបានយាងទៅសំដែងធម៌ទេសនាប្រោសភិក្ខុ ៥ ព្រះអង្គ ព្រោះភិក្ខុ៥អង្គនោះជាក្រុមបញ្ញវន្តអ្នកស្វែងរកការពិតនៃជីវិតដើម្បីរំដោះទុក្ខ ដែលបួសជាតាបសឥសីតាមបម្រើព្រះអង្គ។ ព្រះអង្គសំដែងអំពីជីវិតសន្តិភាពតាមដំណើរការប្រតិបត្តិមជ្ឈិមាបដិបទា ផ្លូវកណ្តាល ដោយទាត់ចោលនូវផ្លូវអមខាងគឺចិត្តត្រេកត្រអាលនឹងកាមគុណ ៥ និងការប្រតិបត្តិធ្វើបាបកាយ។ ផ្លូវកណ្តាលនោះ គឺមគ្គប្រកបដោយអង្គ ៨ រួមឱ្យខ្លីបានដល់សីល សមាធិ និងបញ្ញា។ ភិក្ខុ ៥ អង្គនោះ បានសម្រេចធម៌ជាន់ខ្ពស់ រួចស្រឡះចាកអាសវក្កិលេស សេចក្តីទុក្ខគ្រប់យ៉ាងមានជាតិទុក្ខជាដើម បានត្រូវរំដោះហើយ។ ភិក្ខុ ៥ អង្គ ជាសាវកបានជាសហការីជំនួយព្រះអង្គក្នុងការសំដែងធម៌ទេសនា

ប្រោសមនុស្សសត្វជាបន្តទៅទៀត។ បើព្រះអង្គពុំបានសំដែងធម៌ប្រោសភិក្ខុ ៥ អង្គឱ្យយល់មាគ៌ាពិតឆ្ពោះទៅរកការរំដោះទុក្ខទេ តាបសទាំង ៥ អង្គ ដែលមហាជនសម័យនោះគោរពបូជា នឹងដឹកនាំមហាជនឱ្យប្រតិបត្តិ តាមមាគ៌ារបស់លោក ដែលពុំមែនជាផ្លូវរំដោះទុក្ខ និងនាំឱ្យសង្គមវង្វេងផ្លូវ និងបែកបាក់គ្នា។

បន្ទាប់មក ព្រះពុទ្ធយាងទៅប្រោសព្រះបាទពិម្ពិសារ ព្រះបាទបសេនទិកោសល ជាព្រះមហាក្សត្រគ្រប់គ្រងអំណាចនាសម័យនោះមួយអន្លើ ដោយរាជអាមាត្រដែលស្មើនឹងរដ្ឋមន្ត្រីបច្ចុប្បន្ននេះ ឱ្យ អនុវត្តតាមគន្លងធម៌ ជាពិសេសឱ្យមានទសពិធរាជធម៌ ដែលជាធម៌របស់អ្នកគ្រប់គ្រងអំណាច។ បើអ្នកគ្រប់គ្រងអំណាចគោរពតាមធម៌របស់អ្នកដឹកនាំ នឹងធ្វើឱ្យប្រទេសបានសុខសន្តិភាព និងលូតលាស់ចម្រើន ហើយប្រជាពលរដ្ឋនឹងរួមសាមគ្គីគ្នាយ៉ាងរឹងមាំ ដែលបរទេសពុំអាចចូលមកឈ្លានពានបាន។ ផ្ទុយទៅវិញ បើអ្នកដឹកនាំគ្មានធម៌ក្នុងខ្លួន និងជិះជាន់សង្កត់សង្កិនរំលោភសិទ្ធិប្រជាពលរដ្ឋ ធ្វើឱ្យប្រជាពលរដ្ឋរងទុក្ខវេទនា នោះនឹងធ្វើឱ្យប្រទេសគ្មានសុខសន្តិភាពឡើយ។ សម័យនោះ ព្រះមហាក្សត្រទាំងឡាយមានព្រះបាទពិម្ពិសារជាដើម បានដើរតាមព្រះធម៌នៃព្រះពុទ្ធជាម្ចាស់ ធ្វើឱ្យប្រទេសបានសុខសន្តិភាព

ហើយបានថ្វាយខ្លួនជាញោមឧបដ្ឋាកទំនុកបំរុងព្រះពុទ្ធសាសនា ឱ្យលូតលាស់ចម្រើនថែមទៀត។ មានព្រះមហាក្សត្រខ្លះ ដោយគោរព និងជឿស៊ប់ក្នុងព្រះពុទ្ធ ពេលមានកិច្ចការសំខាន់ក្នុងរដ្ឋ បានទៅក្រាបថ្វាយបង្គំព្រះពុទ្ធដំណាលទូលព្រះអង្គឱ្យបានជ្រាប ដោយចង់ដឹងថាបើមានកិច្ចការពារពុំល្អ ពិតជាព្រះពុទ្ធមានព្រះពុទ្ធីដីកាពុំខានឡើយ។

បន្ទាប់មកទៀត ព្រះពុទ្ធយាងទៅសំដែងធម៌ទេសនា ប្រោសសេដ្ឋី គហបតី អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដូចជា អនាថបិណ្ឌិកសេដ្ឋី នាងវិសាខាជាដើម ឱ្យជនទាំងនោះលុះក្នុងធម៌ កុំយកទ្រព្យសម្បត្តិជាមធ្យោបាយជិះជាន់អ្នកក្រីក្រ តែត្រូវយកទ្រព្យសម្បត្តិទាំងនោះ បូជាសមណព្រាហ្មណ៍អ្នកមានសីល និងធ្វើសង្គហទានដល់អ្នកក្រីក្រលំបាក។ អនាថបិណ្ឌិកសេដ្ឋី នាងវិសាខា មានឈ្មោះក្នុងគម្ពីរបូជាទានចំពោះព្រះពុទ្ធជាម្ចាស់ ហើយបានជួយសង្គ្រោះដល់អ្នកក្រីក្រ អនាថា គ្មានទីពឹង ស្របនឹងឈ្មោះរបស់សេដ្ឋីថា អនាថបិណ្ឌិកសេដ្ឋី ប្រែថា សេដ្ឋីអ្នកជួយសង្គ្រោះដល់អ្នកអនាថា។

ដូច្នេះឃើញថា ព្រះធម៌របស់ព្រះពុទ្ធ ពុំមែនជាធម៌ក្រៅសង្គមឡើយ គឺជាធម៌សម្រាប់សង្គមមនុស្សគ្រប់ជាន់ថ្នាក់ ទាំង

អ្នកកាន់អំណាច ទាំងប្រជាពលរដ្ឋប្រតិបត្តិតាម ជាពិសេស ព្រះអង្គសំដែង ធម៌សង្កត់ធ្ងន់ទៅលើបុគ្គលបីពួកដូចពោលមកហើយ គឺពួកបញ្ញវន្ត ឥស្សរជន និងអ្នកមានទ្រព្យស្តុកស្តម្ភ ឱ្យពួកទាំងនោះមានធម៌ទើបធ្វើឱ្យសង្គមបានសេចក្តីសុខចម្រើន។ ក្រៅពីនោះ ម្តាយឪពុកនិងកូន ស្វាមីនិងភរិយា ចៅហ្វាយនិងកម្មករ គ្រូនិងសិស្សជាដើម ត្រូវមានធម៌រៀងៗខ្លួន គឺត្រូវគោរពមុខងារនាទីរបស់ខ្លួនសង្គ្រោះគ្នាទៅវិញទៅមកដោយព្រះធម៌ កុំឱ្យមានការជិះជាន់គ្នាក្នុងសង្គម។ ដូច្នេះ ព្រះពុទ្ធជាសង្គមវិទូ សំដែងធម៌ដើម្បីឱ្យសង្គមអនុវត្ត។ ព្រះអង្គពុំធ្វើនយោបាយដូចជាគ្រហស្ថទេ ប៉ុន្តែជាគ្រូ ទូន្មានអ្នកនយោបាយ៕

## ១២. ធម៌ដែលនាំឱ្យប្រទេសរឹងមាំ

ក្នុងគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា បានសំដែងអំពីធម៌ ៧ យ៉ាង ដែលធ្វើឱ្យប្រទេសណាយកទៅអនុវត្ត នឹងធ្វើឱ្យប្រទេសនោះរឹងមាំ មានការលូតលាស់ចម្រើន សេចក្តីវិនាសមិនមានឡើយ ហើយបរទេសក៏មិនអាចចូលមកឈ្លានពានបាន។ ធម៌នេះ ព្រះពុទ្ធសំដែងប្រារព្ធចំពោះព្រាហ្មណ៍ម្នាក់ឈ្មោះ វស្សការព្រាហ្មណ៍ ដោយមានសេចក្តីដំណាលថា ព្រះបាទអជាតសត្រូវ សោយរាជ្យក្នុងដែនមគធៈ មានព្រះបំណងទៅវាយយកដែនវជ្ជី។ ព្រះបាទអជាតសត្រូវជាពុទ្ធសាសនិកជន គោរពព្រះពុទ្ធយ៉ាងជ្រាលជ្រៅបំផុត។ មុននឹងព្រះអង្គទៅធ្វើសឹកសង្គ្រាមច្បាំងយកដែនវជ្ជី របស់ពួកក្សត្រវជ្ជី ព្រះអង្គបានប្រើព្រាហ្មណ៍ម្នាក់ ឈ្មោះវស្សការព្រាហ្មណ៍ឱ្យទៅថ្វាយបង្គំព្រះពុទ្ធ ទូលអំពីបំណងរបស់ព្រះអង្គ។ ព្រះបាទអជាតសត្រូវបានចាត់អាមាត្ររបស់ព្រះអង្គ ឱ្យទៅទូលព្រះពុទ្ធនេះ ដោយមានព្រះបំណងថា បើច្បាំងឈ្នះ ឬមិនឈ្នះស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គនឹងបានដឹងការពិត ព្រោះព្រះពុទ្ធមិនដែលមានព្រះពុទ្ធដីកាខុសទេ។ ពេលនោះវស្សការព្រាហ្មណ៍ ជាមហាមាត្ររបស់ព្រះបាទអជាតសត្រូវ បានទៅថ្វាយបង្គំព្រះពុទ្ធ ហើយ

ទូលព្រះអង្គតាមបណ្ដាំរបស់ព្រះរាជាខ្លួន។ ព្រះពុទ្ធ បានជ្រាបអំពីបំណងនេះហើយ ទើបព្រះអង្គត្រាស់ទៅកាន់ព្រះអានន្ទដែលនៅក្បែរនោះថា ម្នាលអានន្ទ ធម៌ ៧ យ៉ាងដែលតថាគតនឹងពន្យល់តទៅនេះ បើពួកក្សត្រដែនវជ្ជីនៅតែប្រព្រឹត្តតទៅទៀត បរទេសមិនអាចចូលទៅឈ្លានពានបានឡើយ។ ធម៌ ៧ យ៉ាងនោះគឺ ១- ពួកក្សត្រដែនវជ្ជីឧស្សាហ៍ប្រជុំគ្នារឿយៗ ដើម្បីពិគ្រោះគ្នារកសេចក្ដីចម្រើន និងការពារកុំឱ្យមានសេចក្ដីវិនាសរបស់ប្រទេសក្នុងបច្ចុប្បន្ន និងទៅអនាគត។ ២- ព្រមព្រៀងគ្នាប្រជុំ និងព្រមព្រៀងគ្នាលើកការប្រជុំ ព្រមទាំងបំពេញការងារតាមមុខងារនាទីរបស់ខ្លួនឱ្យបានល្អត្រឹមត្រូវ។ ៣- មិនបញ្ញត្តបន្ថែម និងមិនដកច្បាប់ដែលពួកក្សត្រមុនៗបានបញ្ញត្តមកហើយ ត្រូវធ្វើតាមច្បាប់ដែលមានមកនោះ។ ៤- ត្រូវធ្វើសក្ការៈគោរពរាប់អាន និងជឿស្ដាប់ពួកក្សត្រដែនវជ្ជីមានព្រះជន្មច្រើន ដែលមានការពិសោធន៍ក្នុងបញ្ហាស្រុកទេស។ ៥- ពួកវជ្ជីក្សត្រ មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល និងពួកកុមារីក្នុងត្រកូលឱ្យនៅរួម។ ពាក្យនេះទំនងជាមិនឱ្យរំលោភស្ត្រី ឬកុមារីក្នុងត្រកូលរបស់ខ្លួន។ ៦- ធ្វើសក្ការៈគោរពរាប់អានបូជាចេតិយ។ ពាក្យនេះតាមអដ្ឋកថា ពោលថា ទីកន្លែងទេវតាដែលគេធ្លាប់គោរពបូជា។ ៧- ម្នាលអានន្ទ ពួកក្សត្រក្នុង

ដែនវជ្ជី តែងមានបំណងថា ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឱ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយដែលមានស្រាប់ហើយ ក៏សូមឱ្យគង់នៅជាសុខ ក្នុងដែនរបស់យើង។

បន្ទាប់ពីព្រះអង្គ មានព្រះពុទ្ធដីកាទៅកាន់ព្រះអានន្ទដូច្នេះហើយ ព្រះអង្គត្រាស់ទៅកាន់វស្សការព្រាហ្មណ៍ជាមហាមាត្រក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ អបរិហានីយធម៌ ដែលប្រែថា ធម៌មិនសាបសូន្យទាំង ៧ នេះ តាំងនៅក្នុងពួកវជ្ជីក្សត្រហើយ បើពួកវជ្ជីក្សត្រនៅតែប្រតិបត្តិធម៌នេះ អស់កាលត្រឹមណា សេចក្ដីចម្រើនតែងមានប្រាកដល់ពួកវជ្ជីក្សត្រ សេចក្ដីសាបសូន្យមិនមានឡើយអស់កាលត្រឹមនោះ។ វស្សការព្រាហ្មណ៍ក្រាបទូលព្រះពុទ្ធថា បពិត្រព្រះគោតមដ៏ចម្រើន ពិតមែនហើយ កាលបើក្សត្រក្នុងដែនវជ្ជីរួបរួមគ្នាកាន់ធម៌ទាំង ៧ នេះ ព្រះបាទអជាតសត្រូវក្នុងដែនមគធៈ ជាព្រះរាជារបស់ខ្ញុំព្រះអង្គ មិនអាចចាប់ពួកវជ្ជីក្សត្រដោយការច្បាំងបានទេ វៀរលែងតែការលួងលោមផ្លូវចិត្ត ឬរកមធ្យោបាយធ្វើឱ្យ បែកបាក់សាមគ្គីគ្នា ធ្វើឱ្យខ្សោយកម្លាំង ទើបប្រទេសដទៃចូលទៅឈ្លានពានបាន។

យោងទៅតាមព្រះពុទ្ធដីកាទៅកាន់វស្សការព្រាហ្មណ៍ដែលចង់ដឹងឱវាទរបស់ព្រះអង្គ អំពីការទៅវាយយកប្រទេសក្នុងដែនវជ្ជីរបស់ព្រះបាទអជាតសត្រូវនគរមគធៈ បញ្ជាក់ថា ដែនវជ្ជីរបស់ក្សត្រវជ្ជី មានការសាមគ្គីគ្នារឹងមាំណាស់ សត្រូវមិនអាចចូលមកឈ្លានពានបានឡើយ ជាពិសេសសពួកក្សត្រវជ្ជីកាន់ធម៌៧ យ៉ាងដូចពោលកមហើយយ៉ាងខ្ជាប់ខ្ជួន។ គោលសំខាន់ក្នុងការអនុវត្ត គឺក្សត្រវជ្ជីបានប្រជុំគ្នាជាញឹកញាប់ជាអចិន្ត្រៃយ៍ ដើម្បីពិគ្រោះគ្នាអំពីបញ្ហាជាតិ យកយោបល់អំពីចាស់ទុំដែលធ្លាប់មានការពិសោធន៍ មិនបញ្ញត្តច្បាប់បន្ថែម និងមិនដកច្បាប់ដែលក្សត្រវជ្ជីមុនៗបានបញ្ញត្តហើយ។ ផ្ទុយទៅវិញ បើក្សត្រវជ្ជីបែកសាមគ្គីគ្នា ដោយការញុះញង់ពីខាងក្រៅ ដែនវជ្ជីនឹងត្រូវវិនាសដោយសត្រូវខាងក្រៅ ចូលមកលុកលុយ។ ព្រះបាទអជាតសត្រូវមិនហ៊ានចូលទៅឈ្លានពានដែនវជ្ជីឡើយ ដោយឃើញកម្លាំងសាមគ្គីរបស់ក្សត្រវជ្ជី និងបានស្តាប់ព្រះឱវាទរបស់ព្រះពុទ្ធជាម្ចាស់ផង។

ព្រះពុទ្ធដីការបស់ព្រះពុទ្ធទៅកាន់វស្សការព្រាហ្មណ៍នេះ ជាមេរៀនដ៏ល្អណាស់សម្រាប់អ្នកដឹកនាំ និងពលរដ្ឋខ្មែរយកទៅសិក្សា ដើម្បីរៀបចំប្រទេសរបស់ខ្លួនឱ្យបានរឹងមាំ។ ពាក្យរបស់

ព្រះពុទ្ធនេះ ហាក់ដូចព្រះអង្គប្រាប់ព្រះបាទអជាតសត្រូវតាមរយៈវស្សការព្រាហ្មណ៍ថា កុំច្បាំងដណ្តើមយកដែនវជ្ជី ព្រះអង្គពុំមានជ័យជំនះឡើយ ព្រោះដែនវជ្ជីមានការសាមគ្គីគ្នាមិនបែកបាក់គ្នាដោយប្រតិបត្តិធម៌ ៧ យ៉ាងដូចពោលខាងលើ តែធម្មតាព្រះពុទ្ធព្រះអង្គពុំពោលដោយចំដូច្នេះទេ ព្រះអង្គពោលជាធម៌ចំពោះ ព្រះអានន្ទឱ្យវស្សការព្រាហ្មណ៍យកទៅប្រាប់ព្រះបាទអជាតសត្រូវ។ ផ្ទុយទៅវិញ បើដែនវជ្ជីមិនប្រតិបត្តិ តាមធម៌៧យ៉ាង បែកបាក់សាមគ្គីគ្នា ពុំមានឯកភាពជាតិ នឹងធ្វើឱ្យប្រទេសទទួលគ្រោះថ្នាក់ពីបរទេស ឈ្លានពាន ជាពិសេសពេលនេះ គឺពីព្រះបាទអជាតសត្រូវដែលបំរុងលើកទ័ពច្បាំង យកប្រទេសនេះជាចំណុះពេលណាដែនវជ្ជីនេះបាក់បែកគ្នា៕

## ១៣. ប្រភេទនៃជំនះ ទទួលផលផ្សេងគ្នា

ពាក្យថា អ្នកឈ្នះតែងជួបប្រទះនូវពៀរ អ្នកចាញ់តែងដេកកើតទុក្ខ អ្នកលះការឈ្នះការចាញ់បានហើយ គឺជាអ្នកស្ងប់តែងដេកនៅជាសុខ នេះចេញមកពីបាលីជាគាថាថា **ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ។**

ពាក្យថា "អ្នកឈ្នះតែងជួបប្រទះនូវពៀរ" មានន័យសេចក្តីថា ជំនះណាមួយកើតអំពីអំពើឈ្លានពាន អំពើកេងប្រវញ្ច័ អំពើរំលោភ គំរាមគំហែង អំពើទុច្ចរិត ដែលចាត់ទុកជាអំពើរំលោភសិទ្ធិមនុស្ស អំពើនេះធ្វើឱ្យគេមានទុក្ខ ជំនះគ្មានយុត្តិធម៌នេះឱកាសល្អណាមួយ អ្នកចាញ់នឹងធ្វើការសងសឹកវិញ ជាជំនះពុំស្ថិតស្ថេរ តែងមានសត្រូវចាំបៀតបៀនជានិច្ច។ ផ្ទុយពីពាក្យខាងលើនេះ បើជំនះណាកើតឡើងប្រាសចាកការបៀតបៀន ជាជំនះត្រឹមត្រូវតាមផ្លូវធម៌ និងមិនខុសនឹងច្បាប់រដ្ឋ ជាជំនះពុំមានពៀរនឹងអ្នកដទៃឡើយ បើមនុស្សគ្រប់ឋានៈគោរពច្បាប់ទាំងអស់គ្នា។ បើឈ្នះដោយអំពីអយុត្តិធម៌ អ្នកឈ្នះតែងមានបញ្ហាជាមួយអ្នកចាញ់។

ពាក្យថា "អ្នកចាញ់តែងដេកកើតទុក្ខ" មានន័យសេចក្ដីថា អ្នកចាញ់ដោយលេងល្បែងស៊ីសងផ្សេងៗក្ដី ការចាញ់ដោយជម្លោះផ្សេងៗក្ដី តែងតែដេកកើតទុក្ខ។ តាមធម្មតា ទឹកចិត្តរបស់មនុស្សសាមញ្ញកាលណាចាញ់ ទោះបីចាញ់ដោយយុត្តិធម៌ក្ដី អយុត្តិធម៌ក្ដីតែងតែកើតទុក្ខ ព្រោះពុំសម្រេចតាមបំណង។ បើមនុស្សគោរពច្បាប់ បើចាញ់ប្រកបដោយយុត្តិធម៌ សុខចិត្តទទួលស្គាល់នូវលទ្ធផលនៃការចាញ់នេះ។ ប៉ុន្ដែបើចាញ់ប្រកបដោយអយុត្តិធម៌វិញ អ្នកចាញ់មិនសុខចិត្ត តែងតែរកមធ្យោបាយដើម្បីយកជ័យជំនះវិញ។

ពាក្យថា "អ្នកលះការឈ្នះការចាញ់បានហើយ គឺជាអ្នកស្ងប់រម្ងៃដេកនៅជាសុខ" តាមផ្លូវធម៌មានអត្ថន័យថា ថ្នាក់ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម ឃើញទោសនៃសង្ខារទាំងឡាយ មានខន្ធ ៥ ជាដើមជាទុក្ខ ជាសភាវធម៌កើតឡើងហើយតែងតែរលត់ទៅវិញជាធម្មតា។ ដោយឃើញការពិត នេះធ្វើឱ្យព្រះទ័យព្រះអង្គស្ងប់មិនជាប់ជំពាក់ដោយចំណង់អ្វីឡើយ។ ការឈ្នះការចាញ់អ្នកដទៃជាបញ្ហារបស់មនុស្សសាមញ្ញ ចំពោះព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម ព្រះអង្គឈ្នះកិលេសតណ្ហាដែលស្ថិតនៅក្នុងព្រះទ័យព្រះអង្គវិញទេ។ ការ

ឈ្នះនូវមារមានកិលេសមារជាដើម គឺជាជំនះពិតប្រាកដមិនត្រឡប់ចាញ់វិញឡើយ ជាជំនះធ្វើឱ្យព្រះអរហន្តគង់នៅជាសុខក្នុងជីវិតបច្ចុប្បន្ន នៅពេលដែលលោកពុំទាន់រំលត់ខន្ធបរិនិព្វាន។ សង្គមមនុស្សដែលពុំបានអប់រំចិត្តតាមផ្លូវព្រះធម៌ បើគិតពីរឿងមារពុំបានគិតពីមារដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឡើយ តែងតែគិតពីមារថាមកអំពីអ្នកដទៃបង្កើតឱ្យមានឡើង។ សេចក្តីពិត តាមព្រះពុទ្ធសាសនា មុននឹងមារខាងក្រៅចូលមកបាន ដោយសារមារខាងក្នុងបើកដៃ។ បានសេចក្តីថា បើចិត្តសៅហ្មងហើយ អកុសលទាំងឡាយក៏កើតមាន ហើយវិបាករបស់អកុសលក៏កើតឡើង កើតបានជាទុក្ខវេទនាទៅតាមអកុសលកម្ម។ បើគេមិនបានពិចារណានូវមារ ដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឱ្យបានច្បាស់លាស់ជាមុនទេ គេតែងតែបន្ទោសអ្នកដទៃ នាំឱ្យបង្កើតជាជម្លោះទាស់ទែងខ្វែងគំនិតគ្នាពាសពេញពិភពលោក ចងពៀរវេរានឹងគ្នារកទីបំផុតគ្មាន រហូតហ៊ានប្រហារជីវិតអ្នកដទៃ ដោយគ្មានធម៌មេត្តា។ ការលះបង់បាននូវអវិជ្ជាតណ្ហាដែលជាឫសគល់នៃការចង់ឈ្នះចាញ់គ្នាបានហើយ ជាបុគ្គលស្ងប់មិនធ្វើនូវបាបទាំងឡាយ នាំឱ្យបុគ្គលបាននូវសេចក្តីសុខ ដូចពុទ្ធភាសិតថា

សេចក្តីសុខដទៃប្រាសចាកសេចក្តីស្ងប់ពុំមានឡើយ គឺមានសេចក្តីស្ងប់ទើបមានសេចក្តីសុខ។

"ការលះការឈ្នះចាញ់" នេះ បើនិយាយតាមផ្លូវលោកវិញ មានន័យសេចក្តីថា សុខចិត្តអនុវត្តតាមរបបប្រជាធិបតេយ្យ គឺឈ្នះក្តីចាញ់ក្តី សុខចិត្តទទួលយកលទ្ធផលដែលមានភាពត្រឹមត្រូវតាមរបបប្រជាធិបតេយ្យនោះ។ បានសេចក្តីថាតាមរបបប្រជាធិបតេយ្យដើម្បីជ្រើសរើសអ្នកដឹកនាំរដ្ឋ គេត្រូវប្រើសន្លឹកឆ្នោតដែលប្រជាពលរដ្ឋបានបោះដោយសេរី និងយុត្តិធម៌។ បើការបោះនោះមានភាពត្រឹមត្រូវហើយ ក៏ទទួលយកទោះបីឈ្នះក្តីចាញ់ក្តី។ ការសុខចិត្តឈ្នះសុខចិត្តចាញ់តាមរបបប្រជាធិបតេយ្យនេះ បានលទ្ធផលមកវិញ គឺការស្ងប់ផ្លូវចិត្ត រមែងដេកជាសុខ ពុំមានសត្រូវជាមួយអ្នកដទៃផង។

ពុទ្ធភាសិតក្នុងប្រធានបទនេះ ជាការបញ្ជាក់នូវភាពខុសគ្នារវាងមនុស្សបុថុជ្ជន និងព្រះអរិយបុគ្គលទាំងឡាយ គឺមនុស្សបុថុជ្ជនតែងតែចង់ឈ្នះចាញ់គ្នាជានិច្ច ទោះបីការឈ្នះចាញ់គ្នានោះពុំប្រកបដោយធម៌ គឺពុំមានយុត្តិធម៌ក៏ដោយ។ ចំណែកព្រះអរិយបុគ្គល ដែលលោកស្ងប់នូវអំពើបាប លោកឃើញទោសការឈ្នះការចាញ់នេះ ទើបព្រះទ័យលោកស្ងប់ ពុំឡើងចុះទៅតាម

អារម្មណ៍នោះឡើយ។ នេះជាចិត្តប្រសើរបស់បុគ្គលជាន់ខ្ពស់ ដែលធ្វើឱ្យខ្លួនលោកបានសុខផង ធ្វើឱ្យអ្នកនៅជុំវិញខ្លួនលោកបានសុខផង៕

## ១៤. ធម៌ជាគ្រឿងចម្រើន ៤ យ៉ាង

ធម៌ជាគ្រឿងចម្រើន ៤ យ៉ាង បាលីថា វុឌ្ឍិធម៌ ប្រែជាសេចក្ដីថា ធម៌ធ្វើឱ្យអ្នកប្រតិបត្តិតាមបាន ចម្រើនសីលធម៌ផង ចម្រើនសម្ភារៈផង ដូចសេចក្ដីអធិប្បាយតទៅនេះ ៖

១- **សប្បុរិសូបសំសេវៈ** ប្រែថា ការចូលទៅជិតសេពគប់សប្បុរស។ ពាក្យថា សប្បុរស បានដល់បុគ្គលដែលប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត ឬជាអ្នកស្ងប់អំពើបាបគ្រប់យ៉ាង ឬអាចហៅពាក្យជំនួសមួយទៀតថា បណ្ឌិត។ សប្បុសជាបុគ្គលដែលបានទូន្មានខ្លួនយ៉ាងល្អ តែងស្ថិតនៅក្នុងកុសលធម៌ជានិច្ចធ្វើប្រយោជន៍ខ្លួន និងប្រយោជន៍សង្គមឱ្យចម្រើនលូតលាស់។ លក្ខណៈរបស់សប្បុរស តែងមានចិត្តជួយឈឺឆ្អាលនឹងសេចក្ដីទុក្ខរបស់អ្នកដទៃ ហើយចង់ឱ្យគេបានសុខ។ ដូច្នេះអ្នកដែលបានចូលទៅជិតសេពគប់លោក រមែងបានទទួលនូវគំនិតដ៏ល្អៗសម្រាប់មាគ៌ាជីវិតឆ្ពោះទៅរកសេចក្ដីសុខចម្រើន។ នៅក្នុងមង្គលសូត្រ មានធម៌មួយកន្លែងពោលស្របគ្នានេះដែរថា កុំសេពគប់នឹងជនពាល ត្រូវសេពគប់នឹងបណ្ឌិត ឬសប្បុរសទើបបានសេចក្ដីសុខចម្រើន។ ព្រះសម្មាសម្ពុទ្ធជាសប្បុរសយ៉ាងខ្ពង់ខ្ពស់បំផុត ហើយអាណិតសព្វសត្វដែលមានទុក្ខយ៉ាងខ្ពស់បំផុត ព្រោះ

បន្ទាប់ពីត្រាស់ដឹង ព្រះអង្គបានសំដែងធម៌ ទេសនាប្រោសសត្វ អស់រយៈកាល ៤៥ព្រះវស្សា។ ជនណាបានទៅថ្វាយបង្គំ ហើយ បានស្តាប់ធម៌ដែលព្រះអង្គសំដែង ហើយយកមកប្រតិបត្តិតាម ជននោះនឹងរួចចាកទុក្ខមានជាតិទុក្ខជាដើម។

២- **សទ្ធម្មស្សវន** ប្រែថា ស្តាប់ពាក្យប្រៀនប្រដៅរបស់ លោកដោយគោរព។ បានសេចក្តីថា បន្ទាប់ពីចូលទៅជិតសេព គប់នឹងសប្បុរសហើយ ត្រូវយកចិត្តទុកដាក់ស្តាប់ពាក្យរបស់ លោកដោយសេចក្តីគោរព។ ចំណេះចេះដឹងគ្រប់យ៉ាងកើតឡើង ពីការសិក្សារៀនសូត្រ និងការស្តាប់នេះឯង។ បើស្តាប់ ហើយ កន្លែងណាមិនយល់ត្រូវសាកសួរ ហើយត្រូវកត់ត្រាទុកក្រែងភ្លេច ថ្ងៃក្រោយ។ បើជួបលោកអ្នកចេះដឹងហើយ ពុំបានស្តាប់ពាក្យ ប្រៀនប្រដៅរបស់លោកទេ ការជួបនេះពុំមានប្រយោជន៍ឡើយ។ ក្នុងព្រះពុទ្ធសាសនា លោកអ្នកដែលបានសម្រេចមគ្គផលនិព្វាន តួយ៉ាងដូចជាព្រះអរហន្ត ដោយសារបានស្តាប់ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធហើយយកមកប្រតិបត្តិតាម។

៣- **យោនិសោមនសិការ** ប្រែថា ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា។ សេចក្តីថា បើបានស្តាប់ពាក្យប្រៀន ប្រដៅរបស់លោកអ្នកសប្បុរសហើយ ត្រូវយកមកគិតពិចារណា

ឱ្យយល់សេចក្តីច្បាស់លាស់។ បើកន្លែងណាមិនយល់ច្បាស់ត្រូវសាកសួរបញ្ជាក់ ដើម្បីកុំឱ្យធ្វើទុកក្នុងចិត្តខុស។ បើស្តាប់ហើយពុំបានពិចារណាឱ្យដក់ជាប់នៅក្នុងចិត្តទេ ការស្តាប់នោះពុំបានផលអ្វីទៀយ ព្រោះពុំបានចាំនៅក្នុងចិត្ត។ បញ្ញាមួយផ្នែកនេះ គឺកើតពីការស្តាប់ តែដើម្បីឱ្យចងចាំច្បាស់លាស់ត្រូវត្រិះរិះពិចារណាឱ្យស្ថិតជាប់ក្នុងចិត្តដែលហៅថា ចិន្តាមយបញ្ញា។ ក្នុងន័យនេះសូម្បីធម៌ដែលព្រះពុទ្ធសំដែងក៏ព្រះអង្គ តែងតែរំលឹកថាចូរអ្នករាល់គ្នាយកធម៌ដែលតថាគតសំដែងទៅពិចារណាទៀត មុននឹងជឿតថាគត។ ត្រង់ពាក្យរំលឹកនេះ ក្នុងព្រះបំណងឱ្យមនុស្សសត្វប្រើបញ្ញាពិចារណាឱ្យយល់ច្បាស់ខ្លួនឯង មិនត្រូវជឿអ្នកដទៃដោយពុំបានយល់ច្បាស់ខ្លួនឯងឡើយ។

៤- **ធម្មានុធម្មប្បដិបត្តិ** ប្រែថា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌។ សេចក្តីថា បើពិចារណា យល់សេចក្តីនូវធម៌នោះហើយ ត្រូវយកមកប្រតិបត្តិទៀត ទើបសម្រេចប្រយោជន៍បាន។ បើគ្រាន់តែដឹងផ្លូវទៅកាន់សេចក្តីសុខ ប៉ុន្តែពុំបានប្រព្រឹត្តតាមទេ សេចក្តីសុខក៏ពុំអាចសម្រេចបានឡើយ។ យ៉ាងណាមិញ ពុទ្ធបរិស័ទចង់រួចចាកទុក្ខសម្រេចព្រះនិព្វាន ត្រូវព្យាយាមស្តាប់ធម៌ទេសនាផ្លូវទៅនិព្វានត្រង់មគ្គប្រកបដោយអង្គ៨ រួចប្រតិបត្តិ

តាម។ ពាក្យថា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ បានសេចក្តីថា ប្រតិបត្តិត្រូវ តាមផ្លូវធម៌មិនឱ្យឃ្លៀងឃ្លាតរហូតដល់ទីបំផុតទុក្ខ។

ធម៌ទាំង ៤ ប្រការនេះ តែងមានទំនាក់ទំនងគ្នា បើពុំបាន អនុវត្តផ្នែកណាមួយពុំអាចសម្រេចប្រយោជន៍ឡើយ។ គឺជាធម៌ សម្រាប់ប្រតិបត្តិទៅរកសេចក្តីសុខចម្រើន។ ធម៌នេះ គេអាចយក ទៅអនុវត្តឱ្យចម្រើនលូតលាស់ខាងសម្ភារៈ សេដ្ឋកិច្ចគ្រួសារ និង សេដ្ឋកិច្ចជាតិ។ ឧទាហរណ៍ ដើម្បីឱ្យចម្រើនលូតលាស់ផ្នែក សង្គមកិច្ច ឱ្យប្រជាពលរដ្ឋរស់នៅមានជីវភាពខ្ពង់ខ្ពស់ គេធ្វើ ផែនការឱ្យប្រជាពលរដ្ឋ ជាពិសេសសិស្ស និងនិស្សិតឱ្យសិក្សាឱ ចេះដឹងនូវបច្ចេកទេសគ្រប់យ៉ាង ពីសាស្ត្រាចារ្យជំនាញការគ្រប់ ផ្នែក ហើយយកមកអនុវត្តតាម។ គោលធម៌ទាំង ៤ ដូចបាន ពោលមកហើយ ចាត់ជាមូលដ្ឋានសំខាន់ ក្នុងការធ្វើឱ្យមានការ ចម្រើនលូតលាស់ខាងសម្ភាៈ ចិញ្ចឹមជីវិត និងខាងសីលធម៌៕

## ១៥. មគ្គប្រកបដោយអង្គ ៨ ជាផ្លូវចេញចាកទុក្ខ

ព្រះសម្ពុទ្ធបានប្រកាសនៅពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោសភិក្ខុ ៥ អង្គថា ផ្លូវអមខាងទាំងពីរគឺទី ១ ឈ្មោះ **កាមសុខល្លិកានុយោគ** ចិត្តត្រេកអរនូវសេចក្តីសុខក្នុងកាមគុណទាំង ៥ គឺ រូប សម្លេង ក្លិន រស និង សម្ផស្ស ជាធម៌របស់អ្នកស្រុក ជាធម៌ថោកទាប ជាធម៌របស់មនុស្សបុថុជ្ជន ពុំមែនជាធម៌របស់អរិយបុគ្គលដែលនាំឱ្យឃើញអរិយសច្ច ៤ ទេ មិនប្រកបដោយប្រយោជន៍ឡើយ ព្រោះការជាប់ចិត្តបែបនេះ នាំឱ្យខ្សោយបញ្ញា មិនអាចត្រាស់ដឹងបានឡើយ តថាគតធ្លាប់បានប្រព្រឹត្តផ្លូវនេះហើយ កាលនៅក្នុងព្រះរាជវាំង ផ្លូវនេះចាត់ទុកជាផ្លូវអមខាងជាផ្លូវស្តាំផុត។ ផ្លូវទី២ឈ្មោះ **អត្តកិលមថានុយោគ** ព្យាយាមប្រព្រឹត្តធ្វើឱ្យលំបាកកាយដោយវិធីផ្សេងៗ មានខែត្រជាក់ចុះត្រាំទឹក ខែក្តៅឈរ ឬអង្គុយហាលថ្ងៃ ឈរតែជើងម្ខាង ដេកលើបន្លា ដកដង្ហើមតិចៗ បន្ថយអាហារ ដើម្បីឱ្យស្ងួតកិលេស ដោយយល់ខុសថាកិលេសនៅក្នុងកាយ ធម៌នេះធ្វើឱ្យលំបាកកាយ មិនមែនជាធម៌របស់អរិយបុគ្គលទេ មិនប្រកបដោយប្រយោជន៍ឡើយ វិធីប្រតិបត្តិបែបនេះក៏តថាគតធ្លាប់បានអនុវត្តហើយ ចាត់ទុកជាផ្លូវអមខាង ជាផ្លូវឆ្វេងផុត។

ព្រះសម្មាសម្ពុទ្ធជាកំពូលនៃលោកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ **មជ្ឈិមាបដិបទា** ជាផ្លូវប្រតិបត្តិជាកណ្តាល ព្រោះឃើញទោសក្នុងផ្លូវអមខាងទាំងពីរ ជាផ្លូវប្រតិបត្តិដើម្បីកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ដើម្បីដឹងចំពោះ ដើម្បីដឹងប្រពៃ ដើម្បីរំលត់ទុក្ខ។ មគ្គប្រកបដោយអង្គ ៨ នេះឯង ហៅថាការប្រតិបត្តិថ្នាក់កណ្តាល គឺ សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ សម្មាសង្កប្បោ ការត្រិះរិះត្រូវ សម្មាវាចា វាចាត្រូវ សម្មាកម្មន្តោ ការងារត្រូវ សម្មាសតិ ការរលឹកត្រូវ និង សម្មាសមាធិ ការដំកល់ចិត្តនឹងត្រូវ។ បើរួមឱ្យខ្លីមានបីគឺ សីល សមាធិ បញ្ញា។ សម្មាទិដ្ឋិ និង សម្មាសង្កប្បោ ជាតួបញ្ញា សម្មាវាចា សម្មាកម្មន្តោ និងសម្មាអាជីវោ ជាតួសីល សម្មាវាយាមោ សម្មាសតិ និងសម្មាសមាធិ ជាតួសមាធិ។ អដ្ឋង្គិកមគ្គនេះលោករៀងបញ្ញានៅខាងដើម ប្លែកពីត្រៃសិក្ខាដែលរៀងបញ្ញានៅខាងចុង គឺសីល សមាធិក បញ្ញា មកពីវិធីបច្ចេកទេសរបស់ព្រះសម្ពុទ្ធក្នុងការសំដែងធម៌ទេសនាប្រោសភិក្ខុ ៥ អង្គ ព្រះអង្គចាំបាច់ត្រូវតែសំដែងអំពីបញ្ញាមុន ដើម្បីឱ្យភិក្ខុទាំង ៥ អង្គយល់ថា ព្រះពុទ្ធត្រាស់ដឹងហើយ ឱ្យភិក្ខុទាំងនោះយកចិត្តទុកដាក់ស្តាប់ ព្រោះសីល និង សមាធិ ភិក្ខុទាំងនោះធ្លាប់អនុវត្តហើយ។

តែអ្នកសិក្សាព្រះពុទ្ធសាសនាគប្បីយល់ថា បញ្ញានេះជាបញ្ញាលោកុត្តរ កើតឡើងបានលុះត្រាតែមានសីល និងសមាធិប្រកបជាមួយ ហើយពុំមែនជាបញ្ញាកើតពីការស្តាប់ និងការត្រិះរិះពិចារណាជាតួបរិយត្តិធម៌ធម៌នោះទេ តែជាតួបញ្ញាកើតពីការប្រតិបត្តិវិបស្សនាភាវនា ទើបកើតបញ្ញាលោកុត្តរ ជាបដិវេធធម៌ឃើញអរិយសច្ច ៤។ ការដើរតាមមគ្គប្រកបដោយអង្គ ៨ ឃើញអរិយសច្ច ៤ គឺ សេចក្តីទុក្ខបានដល់ការកើតឡើងនៃខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ១ ហេតុដែលនាំឱ្យកើតទុក្ខ បានដល់តណ្ហា១ ការរំលត់ទុក្ខបានដល់និព្វាន១ ផ្លូវទៅកាន់ការរំលត់ទុក្ខបានដល់មគ្គ ប្រកបដោយអង្គ ៨ ដូចបានពោលមកហើយ១ (ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច)។ ការត្រាស់ដឹងរបស់ព្រះពុទ្ធនេះ មិនត្រឹមតែមនុស្សលោកទេដែលមានការរំភើបសប្បាយរីករាយ ដំណឹងនេះ បានដឹងយ៉ាងឆាប់រហ័សដល់ពពួកទេវតា ពួកព្រាហ្មណ៍ បានសំដែងការកោតសសើរចំពោះព្រះពុទ្ធឈ្នះមារបានត្រាស់ដឹង រកឃើញការពិតនៃការរំដោះទុក្ខរបស់មនុស្សសត្វ ដែលពីមុនមកគ្មានអ្នកណារកឃើញ ហើយសង្ឃឹមថាខ្លួននឹងបានស្តាប់ធម៌ព្រះអង្គក៏ថ្វាយពរសព្វសាធុការតែរៀងៗខ្លួន។

មគ្គប្រកបដោយអង្គ ៨ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ជាផ្លូវនៃការចេញចាកទុក្ខ បានដល់អមតមហានិព្វាន។ សមណព្រាហ្មណ៍ និងតាបសឥសីមុនសម័យពុទ្ធកាលក៏ដូចជាសម័យពុទ្ធកាល មិនបានឃើញនូវផ្លូវនេះទេ ក្រោយពីព្រះអង្គបានសិក្សាពិសោធគ្រប់បែបយ៉ាង នឹងដោយបារមីធម៌ដែលព្រះអង្គបានកសាងជួយជម្រុញផង ទើបព្រះអង្គរកផ្លូវត្រាស់ដឹងនេះឃើញ ហើយដោយព្រះអង្គប្រតិបត្តិតាមផ្លូវនេះ (មគ្គ ៨) ក៏បានត្រាស់ជាព្រះពុទ្ធក្នុងលោក គឺការឃើញអរិយសច្ច ៤ នេះឯង។ សាសនាដទៃស្វែងរកសេចក្តីសុខតែនៅក្នុងខន្ធ ៥ មានរូបខ្លួនជាដើម ក្នុងឋានមនុស្ស ឋានទេវតា និងឋានព្រហ្ម។ ព្រះពុទ្ធសំដែងថា ភពទាំងបីនេះស្ថិតនៅក្រោមត្រៃលក្ខណធម៌ គឺ អនិច្ចំ ទុក្ខំ និង អនត្តា កើតចាស់ឈឺស្លាប់ មិនរួចពីសេចក្តីទុក្ខឡើយ ជាវដ្តសង្សារវិលស្លាប់វិលកើតចាស់ឈឺស្លាប់រកទីបំផុតគ្មាន។ ចំណែកព្រះនិព្វានទើបដល់នូវការរំលត់ទុក្ខ ពុំស្ថិតនៅក្រោមអំណាចមច្ចុរាជឡើយ។ យើងបានឃើញរឿងក្នុងសាសនាព្រាហ្មណ៍ និកាយព្រះវិស្ណុថា ពួកទេវតា និងពួកអសុរបានកាន់ក្បាលនាគ និងកន្ទុយនាគម្ខាងម្នាក់កូរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្រឹតផឹកទៅមិនស្លាប់។ នេះជារឿងដំណាលប្រាសចាកការពិត របស់សាសនាព្រាហ្មណ៍

ព្រោះអ្វី ព្រោះថាគ្មានទឹកណាផឹកទៅមិនស្លាប់នោះឡើយ កាលណាបើមានជាតិតែងតែបញ្ជូនទៅរកជរាព្យាធិ និងមរណៈពុំខានឡើយ។ ចំណែកព្រះនិព្វានទើបមិនស្លាប់ ទើបហៅថា អមតមហានិព្វាន។ ក្នុងធម៌អារាធនាព្រហ្មថា ញ៉ាំងសត្វចូលពុទ្ធចក្រមានបញ្ចវគ្គីជាអាទិ៍ ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា។ ពាក្យថា អម្រឹតជាពាក្យសំស្ក្រឹតប្រែថា មិនស្លាប់ ស្មើគ្នានឹងពាក្យបាលីថា អមតំ បានជាលោកពោលថា អមតំ និព្វានំ ប្រែថានិព្វានមិនស្លាប់។ ដូច្នេះ បានសេចក្ដីថា ផឹកអម្រឹតជាតិ គឺប្រតិបត្តិតាមមគ្គប្រកបដោយអង្គ ៨ ដូចបានពោលមកហើយទើបបានរសមួយ គឺនិព្វានជាធម៌មិនស្លាប់ លែងវិលកើតវិលស្លាប់ក្នុងវដ្ដសង្សារជាបន្តទៅទៀត៕

## ១៦. ពុទ្ធភាសិត ៤ បទ ដែលនាំឱ្យឈ្នះ

ធម៌ ៤ បទជាពុទ្ធភាសិតដែលនាំឱ្យឈ្នះ គឺធម្មទានរមែងឈ្នះនូវទានទាំងពួង រសព្រះធម៌ រមែងឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហា រមែងឈ្នះសេចក្តីទុក្ខទាំងពួង នេះចេញមកពីបាលីថា **សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ សព្វរត្តឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ពាក្យថា ធម្មទានរមែងឈ្នះនូវទានទាំងពួង មានសេចក្តីថា ទានប្រែថាការឱ្យមានពីរយ៉ាងគឺៈ អាមិសទាន ការឱ្យវត្ថុផ្សេងៗជាទាន និងធម្មទាន ប្រែថា ការឱ្យទានធម៌ គឺការប្រាប់ពន្យល់បាបបុណ្យ គុណទោស ល្អអាក្រក់ ការប្រាប់មធ្យោបាយផ្សេងៗដែលនាំទៅរកសេចក្តីសុខចម្រើន តាមមាគ៌ាព្រះពុទ្ធសាសនា។ ទានទាំងពីរនេះ ធម្មទានរមែងឈ្នះអាមិសទាន ព្រោះថាអាមិសទានដែលលះវត្ថុផ្សេងៗធ្វើជាទានឱ្យបានត្រឹមត្រូវ មកពីបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោកអ្នកសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម គឺធម្មទាននេះឯង។ ឧទាហរណ៍ ការឱ្យផ្លែស្វាយមួយទទួលទានតែម្តងក៏អស់ទៅ ប៉ុន្តែបើគេ ឱ្យគ្រាប់យកទៅដាំ ហើយប្រាប់មធ្យោបាយដាំ លុះស្វាយនោះដុះជាដើមបែកជាមែកមាន

ផ្កាផ្លែ គេនឹងបេះបានរាល់ឆ្នាំ នេះដោយសារការប្រាប់វិធីដាំ ដែលហៅថាធម្មទាននេះឯង។

ពាក្យថារសនៃព្រះធម៌រមែងឈ្នះរសទាំងពួង មានសេចក្តីថា រសទាំងឡាយ ដូចជារសក្នុងកាមគុណ ៥ មានការសប្បាយរីករាយតែមួយខណៈពេល ដោយការប៉ះអារម្មណ៍ក៏បាត់ទៅវិញ។ ការឃើញរូប ក៏កើតការស្រឡាញ់ជាប់ចិត្តនឹងរូបសប្បាយបានតែមួយខណៈពេលក៏បាត់ទៅវិញ។ ការឮសម្លេង បើសម្លេងនោះជាទីគាប់ចិត្ត ក៏បានរីករាយតែក្នុងរយៈពេលខ្លីក៏បាត់ទៅវិញ។ ការធុំក្លិនក្រអូប ធ្វើឱ្យចិត្តរីករាយបានតែមួយភ្លែតក៏បាត់ទៅវិញ។ អណ្តាតបានប៉ះរសជាតិអាហារឆ្ងាញ់ពិសារ បានតែមួយរយៈពេល លុះលេបផុតពីបំពង់កទៅការឆ្ងាញ់ពិសារនោះក៏បាត់ទៅ។ កាយប៉ះផោដ្ឋព្វ គឺប៉ះរបស់ល្អប្រណីត ធ្វើឱ្យកាយសុខស្រួលបានតែមួយពេលក៏បាត់ទៅវិញ។ ចិត្តនឹកគិតអារម្មណ៍ ជាទីគាប់ចិត្តបានរីករាយចិត្តតែមួយខណៈពេលក៏បាត់ទៅវិញ។ រសជាតិនៃសេចក្តីសុខនេះ លោកហៅថាកាមសុខ ឬអាមិសសុខ គឺសុខដោយការប៉ះអារម្មណ៍។ ឯរសរបស់ព្រះធម៌ គឺសីល សមាធិបញ្ញា បើបុគ្គលណាបានប្រតិបត្តិតាមនឹងរួចចាកទុក្ខ គឺវិមុត្តិរស ឬនិព្វានរស ចេញផុតពីការកើតចាស់ឈឺស្លាប់។

ពាក្យថា សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង មានសេចក្តីថា ការត្រេកអរក្នុងធម៌ រីករាយក្នុងធម៌ ស្រឡាញ់ធម៌ ហើយធ្វើតាមធម៌ គឺប្រតិបត្តិតាមមគ្គប្រកបដោយអង្គ ៨ បើរួមឱ្យខ្លីបានដល់ សីល សមាធិក បញ្ញា ដែលព្រះពុទ្ធបានរកឃើញ ជាផ្លូវនៃសេចក្តីបរិសុទ្ធ ជាផ្លូវនៃការចេញចាកទុក្ខ បានដល់ព្រះនិព្វាន ឆ្លងផុតពីភពបី ដែលជាភពស្ថិតនៅក្រោម អនិច្ចំ ទុក្ខំ និង អនត្តា។ ដូច្នេះ សេចក្តីត្រេកអរក្នុងធម៌ ហើយប្រតិបត្តិតាមនឹងរួចចាកទុក្ខ ឯសេចក្តីត្រេកអរផ្សេងពីព្រះធម៌ ដូចជាត្រេកអរក្នុងកាមគុណ ៥ មានរូបជាដើម ពុំអាចធ្វើទុក្ខឱ្យអស់ទៅបានឡើយ។

ពាក្យថា ការអស់ទៅនៃតណ្ហា រមែងឈ្នះនូវសេចក្តីទុក្ខទាំងពួង មានសេចក្តីថា សេចក្តីទុក្ខកើតមានព្រោះមានហេតុនាំឱ្យមានទុក្ខ។ ក្នុងអរិយសច្ច ៤ ប្រែថា ការពិត ៤ យ៉ាង ទីមួយគឺសេចក្តីទុក្ខ បានដល់ការកើតឡើងនៃខន្ធ ៥ មានរូបក្ខន្ធជាដើម ជាទុក្ខត្រូវកំណត់ដឹង។ ទីពីរ ហេតុដែលនាំឱ្យកើតទុក្ខបានដល់តណ្ហាត្រូវលះបង់។ ទីបី និរោធសច្ច បានដល់ព្រះនិព្វានត្រូវធ្វើឱ្យជាក់ច្បាស់។ ទីបួន មគ្គសច្ច បានដល់មគ្គប្រកបដោយអង្គ ៨ ការអស់ទៅនៃតណ្ហា ទើបអស់ទុក្ខទាំងពួងដែលធ្វើឱ្យជាក់ច្បាស់

នូវព្រះនិព្វានជាការរំលត់ទុក្ខគឺរំលត់នូវខន្ធ ៥ កុំឱ្យកើតមានតទៅទៀត ព្រោះការកើតឡើងនៃខន្ធ ៥ នេះហើយ ដែលនាំឱ្យកើតចាស់ឈឺស្លាប់ក្នុងសង្សារវដ្តរកទីបំផុតគ្មាន បើគេពុំឃើញអរិយសច្ច ៤ នេះទេ៕

## ១៧. ប្រវត្តិព្រះពុទ្ធសាសនាចូលមកកម្ពុជា

តាមឯកសារបញ្ជាក់ថា ប្រទេសកម្ពុជា និងជនជាតិខ្មែរ កើតមុនសម័យប្រវត្តិសាស្ត្រទៅទៀត គឺសម័យបុរេប្រវត្តិ ប៉ុន្តែអ្នកប្រវត្តិសាស្ត្រពុំបានកត់ត្រាទុក គេដឹងបាននៅសម័យនោះដោយ កំណប់ និងដំណែលដែលគេរកឃើញសព្វថ្ងៃនៅស្ថានីយ៍បុរេប្រវត្តិសំរោងសែន (ខេត្តកំពង់ឆ្នាំង) អន្លង់ផ្តៅ (អគ្នេយ៍ នៃសំរោងសែនប្រមាណ៣០គ.ម) ម្លូព្រៃ (ខេត្តព្រះវិហារ)។ សម័យបុរេប្រវត្តិនៃប្រទេសកម្ពុជា បានចាប់ផ្តើមក្នុងយុគថ្មរំលីង មកទល់នឹងសតវត្សរ៍ទី១នៃ គ.ស មានរយៈកាលជាង ២០ សតវត្សរ៍។ នៅសតវត្សរ៍ទី១នៃ គ.ស ទើបប្រទេសខ្មែរចាប់ផ្តើមប្រវត្តិសាស្ត្ររបស់ខ្លួនច្បាស់លាស់។ ដូច្នេះ ជនជាតិខ្មែរមកតាំងទីលំនៅនៅជ្រោយឥណ្ឌូចិនមុនគេបង្អស់។ ឈ្មោះប្រទេសកម្ពុជាពីដើម តាមឯកសារខ្មែរថា នគរគោកធ្លក ឯកសារបរទេសថា នគរភ្នំឬហ្វូណន ក្រោយមកហៅថាចេនឡា។ នៅពេលនោះជនជាតិខ្មែរ គោរពសាសនាព្រលឹងនិយម (animism) គឺយល់ថាសព្វសារពើវត្ថុទាំងអស់សុទ្ធតែមានព្រលឹងវិញ្ញាណ ក្រោយមកគោរពខ្មោចអារក្សអ្នកតា។

តាមគម្ពីរពុទ្ធសាសនា សមន្តបាសាទិកា អដ្ឋកថាវិន័យបិដកជាភាសាបាលី បាននិយាយថា ក្រោយការធ្វើតតិយសង្គាយនានៅជម្ពូទ្វីប គឺប្រទេសឥណ្ឌាក្នុងពុទ្ធសតវត្សរ៍ទី៣ គឺព.ស ២៣៦ (មុនគ.ស ៣០៩ឆ្នាំ) ព្រះមហាថេរមួយព្រះអង្គព្រះនាមមហាមោគ្គលិបុត្តតិស្សត្ថេរ បានចាត់សមណទូត ២ ព្រះអង្គ គឺព្រះសោណត្ថេរ និងឧត្តរត្ថេរ ឱ្យនិមន្តពីប្រទេសឥណ្ឌាមកផ្សាយព្រះពុទ្ធសាសនានៅជ្រោយ សុវណ្ណភូមិ ក្នុងព្រះរាជូបត្ថម្ភនៃព្រះមហាក្សត្រព្រះនាម ធម្មាសោក។ សុវណ្ណភូមិគឺប្រទេសនៅអាស៊ីភាគអាគ្នេយ៍។ ប្រទេសនៅអាស៊ីភាគអាគ្នេយ៍បានអះអាងថា សុវណ្ណភូមិ គឺនៅត្រង់ប្រទេសរបស់ខ្លួន ចំណែកប្រទេសកម្ពុជាក៏អះអាងថា សុវណ្ណភូមិ គឺនៅត្រង់ប្រទេសរបស់ខ្លួនដែរ ដោយសំអាងទៅលើប្រវត្តិសាស្ត្រចាស់ទុំរបស់ខ្លួន។ ព្រះពុទ្ធសាសនាក៏បានប្រតិស្ឋាននៅជ្រោយសុវណ្ណភូមិ ដោយព្រះថេរៈទាំងពីរព្រះអង្គនេះ។

ក្រៅពីឯកសារនេះ មានឯកសារមួយទៀតនិយាយថា មានពួកពាណិជសំពៅសមុទ្របាននាំភិក្ខុសង្ឃមកផ្សាយព្រះពុទ្ធសាសនា ហើយបាននាំព្រះពុទ្ធរូបយកទៅប្រតិស្ឋានទុកនៅទីកន្លែងនានា ដែលខ្លួនបានទៅតាំងទីលំនៅ ប្រកបការរកស៊ី

ចិញ្ចឹមជីវិតថែមទៀត។ បានសេចក្ដីថា ពួកនោះបានមកដល់ជ្រោយសុវណ្ណភូមិ មិនមែនគ្រាន់តែប្រកបរបរអាជីវកម្មលក់ដូរប៉ុណ្ណោះទេ ថែមទាំងឆ្លៀតយកឱកាសដ៏ប្រពៃនេះផ្សាយព្រះពុទ្ធសាសនា ហើយបានរួបរួមជាមួយអ្នកម្ចាស់ស្រុកដើមកសាងវត្តអារាមសំរាប់ភិក្ខុសង្ឃនិងប្រតិស្ឋានព្រះពុទ្ធរូបថ្វាយគ្រឿងសក្ការបូជាញុាំងព្រះពុទ្ធសាសនាឱ្យចាក់ឫសគល់នៅទីឋាន នោះៗទៀត។

ឯកសារមួយទៀតនិយាយថា ក្នុងរាជព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នបានបញ្ជូនភិក្ខុខ្មែរពីរអង្គនេះ គង់នៅប្រទេសនេះក្នុងរវាងចុងគ្រិស្តសតវត្សរ៍ទី ៥ និងខាងដើមគ្រិស្តសតត្សរ៍ទី៦ ព្រះថេរៈមួយអង្គ នាម សង្ឃបាលោ ជួយប្រែព្រះត្រៃបិកដអស់រយៈកាល ១៦ឆ្នាំ ពី គ.ស ៥០៦ ដល់ គ.ស ៥២២ រួមជាមួយភិក្ខុខ្មែរមួយអង្គទៀតព្រះនាម មន្ទសេន។ សេចក្ដីប្រែជាស្នាព្រះហត្ថនៃព្រះថេរៈទាំងពីរព្រះអង្គនេះ បានជាប់ព្រះនាមក្នុងព្រះត្រៃបិដកចិនរហូតមកដល់បច្ចុប្បន្ននេះ កន្លែងបំពេញកិច្ចនេះហៅថា ហ្វូណនក្វាង ប្រែថា ការិយាល័យប្រទេសនគរភ្នំ។

ក្នុងរជ្ជកាលនៃព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និងព្រះបាទរុទ្រវរ្ម័ននេះ ព្រះពុទ្ធសាសនារុងរឿងណាស់ លោកសីដេសដែលអ្នកស្រាវជ្រាវជាតិបារាំងសរសេរថា ព្រះពុទ្ធសាសនាថេរវាទភាសា

សំស្ក្រឹតបានកើតមានហើយនៅក្នុងប្រទេសខ្មែរ កាលពីគ្រិស្តសតវត្សរ៍ទី ៣ នោះ មានការចម្រើនរុងរឿងណាស់ ក្នុងគ្រិស្តសតវត្សរ៍ទី ៥ និងទី ៦។ សម័យនោះ មានកើតព្រះពុទ្ធរូបជាច្រើនព្រះអង្គធ្វើអំពីថ្ម ពីសំរឹទ្ធ ពីឈើ ជារចនាខ្មែរ។ ភ្នំដានៅអង្គរបុរី ស្រុកព្រៃកប្បាស ខេត្តតាកែវ ជាមជ្ឈមណ្ឌលនៃការកសាងព្រះបដិមាទាំងនោះ មានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់។ បដិមាជាការរចនាបែបភ្នំដា ផ្សាយទូទៅពេញផែនដីនគរភ្នំ និងនៅតំបន់ជិតខាង។ ការរៀបរាប់នេះ បញ្ជាក់ថា ព្រះពុទ្ធសាសនាថេរវាទចម្រើនរុងរឿងណាស់ក្នុង សម័យនគរភ្នំ។

អំពីកំពង់ផែអុកអែវ គឺជាកំពង់ផែដ៏ធំនៅមាត់សមុទ្រប្រទេសកម្ពុជាពីបុរាណ។ នៅកំពង់ផែនេះ គេបានរកឃើញបុរាណវត្ថុដែលមានអាយុតាំងពីគ្រិស្តសតវត្សរ៍ទី១ មានរូបផ្សេងៗ ដូចជារូបអ្នកស្រុក ទេវរូប ព្រះពុទ្ធរូប និងរូបិយវត្ថុរបស់ជាតិរ៉ូម៉ាំង ជាតិឥណ្ឌា អក្សរព្រហ្មីជាដើម។ មានព្រះកេសព្រះពុទ្ធរូបមួយព្រះអង្គល្អវិសេសធ្វើពីសំរឹទ្ធិ តាមរបាយការណ៍របស់អ្នកស្រាវជ្រាវម្នាក់និយាយថា ព្រះកេស ព្រះពុទ្ធរូបនេះ កើតតាំងពីខាងដើមគ្រិស្តសករាជម្ល៉េះ ការរចនាបែបគន្ធារៈ។ ដូច្នេះកំពង់ផែអុកអែវ ឬអូកែវដែលសព្វថ្ងៃនៅលើដីវៀតណាមពីដើមជារបស់ខ្មែរ គួររាប់

ថាជាគមនាគមន៍រវាងឥណ្ឌា និងអាស៊ីភាគអាគ្នេយ៍។ អ្នកប្រាជ្ញទាំងឡាយពោលថា ដើមហេតុដែលនាំឱ្យជនជាតិឥណ្ឌាមកកាន់សុវណ្ណភូមិនោះ មិនមែនមានដើមហេតុដទៃទេ គឺហេតុតែត្រូវការរកមាសជាធំបានជាកើតពាក្យថា សុវណ្ណភូមិ ប្រែថាទី ឬប្រទេសមានមាសនេះឡើង។

នៅសម័យចេនឡា ព្រះបាទជ័យវរ្ម័នទី១ ក្នុងគ.ស ៦៥៧ ដល់ ៦៨១ ពុទ្ធសាសនាថេរវាទចម្រើនរុងរឿងណាស់។ មានសិលាចារឹកមួយនៅសម្បូណ៌ព្រៃគុក ខេត្តកំពង់ធំ គ.ស ៦២៦ បញ្ជាក់ថា មានព្រះពុទ្ធសាសនាមានការគោរពព្រះពុទ្ធរូបប្រក់នាគ។ មានសិលាចារឹកនៅវត្តព្រៃវៀរ គ.ស ៦៦៤ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (កាលដើមជាខេត្តបាភ្នំ) បានចែងថា មានភិក្ខុពីរអង្គជាបងប្អូនបង្កើត ជាតិជាក្សត្រទ្រង់ចេញទៅសាងបព្វជ្ជាហើយគង់នៅវត្តព្រៃវៀរនេះ។ សិលាចារឹកទាំងនេះ ជាសក្ខីភាពពី ១៣០០ឆ្នាំកន្លងមកហើយ។ ឯភាសានិយាយមានតាំងពីកកើតជនជាតិខ្មែរមក ដែលអ្នកប្រាជ្ញខាងសូនវិទ្យាបានចាត់ចូលក្នុងក្រុមខ្មែរមន។ លុះដល់សម័យព្រះបាទជ័យវរ្ម័នទី៧ រាជធានីនគរធំ គ.ស ១១៨១ ប្រទេសកម្ពុជាបានចម្រើនលូតលាស់គ្រប់វិស័យមានវិស័យព្រះពុទ្ធសាសនាជាដើម៕

## ១៨. បាចអង្កាមប្រាសខ្យល់ ឈាមស្រែកស្បែកហៅ

ពាក្យថា "បាចអង្កាមប្រាចខ្យល់" មានពាក្យបី គឺបាច១ អង្កាម១ និងប្រាសខ្យល់១។ អង្កាមគឺ ជាសំបករបស់ស្រូវ ដែលគេកិនហើយអុំចោល ជាវត្ថុស្តើងស្រាល។ បាច គឺគ្រវែងទៅ ឬចោលទៅ។ ប្រាសខ្យល់ គឺបាចបញ្ច្រាសទិសខ្យល់ បើខ្យល់បក់មកពីទិសខាងត្បូង តម្រង់ទៅទិសខាងជើង អ្នកបាចអង្កាមបាចពីទិសខាងជើង តម្រង់ទៅទិសខាងត្បូងអង្កាមនោះពុំអាចមានសន្ទុះទៅមុខបានឡើយ រមែងហើរត្រឡប់មករកម្ចាស់អ្នកបាចវិញ។ ពាក្យនេះមានន័យសេចក្តីប្រៀបធៀបមកអ្នកធ្វើអំពើអាក្រក់ អំពើអាក្រក់នោះរមែងត្រឡប់ឱ្យផលដល់អ្នកធ្វើវិញ។ មួយទៀត អំពើអាក្រក់ដែលគេប្រព្រឹត្តទៅលើជនណាម្នាក់ដែលជាជនឥតទោស អំពើអាក្រក់នឹងត្រឡប់ឱ្យផលអាក្រក់ ដល់ខ្លួនអ្នកប្រព្រឹត្តវិញ។ បានសេចក្តីថា អំពើអាក្រក់គ្រប់យ៉ាង ដែលគេបានធ្វើហើយ តែងផ្តល់ផលដល់អ្នកប្រព្រឹត្តវិញជាដរាប។ អំពើអាក្រក់ដែលគេប្រព្រឹត្តទៅលើតែជនម្នាក់បាបនោះមានទំហំតូច តែបើប្រព្រឹត្តទៅលើជនច្រើនគ្នា បាបនោះមានទំហំធំ។ បាបមានទំហំធំបែបនេះច្រើនអ្នកមានអំណាចប្រព្រឹត្តទៅលើប្រជាពលរដ្ឋរបស់ខ្លួន។ ហេតុយ៉ាងណា ផលយ៉ាងនោះ ឬកម្មបែបណា ផលបែបនោះ

នេះជាពាក្យរបស់ព្រះពុទ្ធសាសនា។ បានសេចក្ដីថា អំពើអាក្រក់ក្ដី ល្អក្ដី គេនឹងទទួលផលនៃអំពើនោះតាមទំហំនៃអំពើរបស់ខ្លួន។ ដូចជាតុលាការដែលមានយុត្តិធម៌នៃផ្លូវអាណាចក្រ ក៏គេកាត់សេចក្ដីឱ្យមានទោសធ្ងន់ស្រាល ស្របតាមកំហុសរបស់អ្នកប្រព្រឹត្តយោងតាមច្បាប់របស់រដ្ឋនីមួយៗ។ ដូច្នេះ ពាក្យថាបាចអង្កាមច្រាសខ្យល់ អង្កាមរមែងត្រឡប់មកដល់អ្នកបាចវិញ ជាពាក្យបង្ហាញស្របតាមផ្លូវធម៌ និងផ្លូវលោកថា បើគេប្រព្រឹត្តអាក្រក់ គេនឹងទទួលផលអាក្រក់។ អត្ថន័យផ្លូវធម៌មានន័យពិសេសជាងផ្លូវលោក ត្រង់អំពើអាក្រក់ និងអំពើល្អ ទោះបីការប្រព្រឹត្តនោះ គ្មានគេឃើញ និងដឹងឮក៏ដោយក៏ត្រូវទទួលផលនៃអំពើអាក្រក់នោះនៅពេលណាមួយពុំខានឡើយ។ ចំពោះតុលាការដែលកាត់សេចក្ដីមិនប្រកបដោយយុត្តិធម៌ ដោយលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះភ័យខ្លាច និងព្រោះល្ងង់ អ្នកកាត់សេចក្ដី ដែលមិនប្រកបដោយយុត្តិធម៌នោះ នឹងទទួលផលអាក្រក់មកខ្លួនវិញ។

ពាក្យថា "ឈាមស្រែកស្បែកហៅ" ជាពាក្យរបស់ចាស់បុរាណខ្មែរ ស្របនឹងព្រះពុទ្ធសាសនាថា អ្នកដែលសាងបាបកម្មធ្ងន់ៗ មានការប្រហាជីវិតមនុស្សជាដើម បាបនោះនឹងស្រែកហៅ

បុគ្គលនោះឱ្យមកទទួលផល។ មួយទៀត អ្នកដែលបំផ្លាញជីវិតគេ អ្នកនោះនឹងទទួលការសងសឹកវិញ ឈាមសងឈាម ជាពិសេសជនពាលប្រព្រឹត្តឧក្រិដ្ឋ មកលើអ្នកមានគុណធម៌ខ្ពស់ ជនពាលនោះនឹងទទួលផលនៃអំពើបាបក្នុងបច្ចុប្បន្នទាន់ហន់។ នៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាមានដំណាលថា ព្រះមោគ្គល្លាន បានសម្រេចជាព្រះអរហន្តថែមទាំងមានឫទ្ធិទៀតផង តែត្រូវចោរវាយធ្វើគត់រហូតរំលត់ខន្ធបរិនិព្វាន ដោយទោសដែលលោកបានធ្វើឃាតមាតាបិតារបស់លោក កាលពីជាតិមុនគឺឈាមរបស់អ្នកមានគុណបានស្រែកហៅរកលោកដើម្បីដាក់ទោស។ យ៉ាងណាមិញ ជនពាលដែលសម្លាប់មនុស្សដោយការចងគំនុំ ធម្មតាក្តី ដោយផ្លូវនយោបាយក្តី ត្រូវឈាម និងស្បែករបស់អ្នកដែលគេសម្លាប់ស្រែកហៅដោយការឈឺចាប់ឱ្យទទួលការឈឺចាប់ដូចគ្នា។ វាលពិឃាតរបស់ខ្មែរក្រហម ដែលមានបរទេសនៅពីក្រោយបានសម្លាប់ពលរដ្ឋខ្មែរយ៉ាងសាហាវព្រៃផ្សៃបំផុត ដែលប្រវត្តិសាស្ត្រពិភពលោកពុំដែលកើតមាន។ អ្នកដែលសាងបាបកម្មដ៏សាហាវនេះ នឹងគេចមិនផុតអំពីការទទួលផលបាបដែលខ្លួនបានសាងឡើយ គឺឈាមស្រែកហៅតុលាការអន្តរជាតិជួយ

រកយុត្តិធម៌ឱ្យខ្លួន ហើយពួកឧក្រិដ្ឋនោះស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចគេច្រានទម្លាក់។

ពាក្យថា បាចអង្កាមច្រាសខ្យល់ និងពាក្យថាឈាមស្រែកស្បែកហៅ ជាពាក្យបុរាណខ្មែរទាក់ទងនឹងព្រះពុទ្ធសាសនាដែលមានអត្ថរសប្រៀនប្រដៅថា អំពើបាបគ្រប់យ៉ាងដែលគេបានប្រព្រឹត្តមកលើអ្នកដទៃ ដែលមានលក្ខណៈរំលោភសិទ្ធិមនុស្ស អំពើបាបនោះនឹងផ្តល់ផលឱ្យអ្នកប្រព្រឹត្តវិញ ពុំអាចគេចផុតឡើយ ដូច្នេះត្រូវជៀសវាងកុំប្រព្រឹត្តអំពើអាក្រក់គ្រប់យ៉ាង ទោះបីអំពើអាក្រក់មានភាពតិចតួចក៏ដោយ៕

## ១៩. បៀតបៀនបុគ្គលដទៃនឹងជាប់ជំពាក់ពៀរ

គាថាមួយបទនៅក្នុងធម្មបទនៃគម្ពីរពុទ្ធសាសនាពោលថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឱ្យកើតមានដល់បុគ្គលដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជំពាក់ គឺពៀរ នឹងមិនរួចផុតអំពីពៀរវេរានេះ ចេញមកពីបាលីថា **បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ** ។ អត្ថន័យនៃគាថានេះ គឺមនុស្សគ្រប់រូបតែងតែប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ចង់ឱ្យខ្លួនរស់នៅបានចម្រើនរុងរឿង បែរជាមានមនុស្សខ្លះប្រព្រឹត្តផ្ទុយពីហេតុដែលនាំឱ្យបានសេចក្តីសុខ គឺប្រព្រឹត្តធ្វើអំពើអាក្រក់ប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃទៅវិញ។ ព្រះពុទ្ធសំដែងថា មនុស្សកើតមកត្រូវបំពេញការងារត្រឹមត្រូវ ការងារពុំមានទោស ការងារដែលមិនធ្វើឱ្យអ្នកដទៃមានទុក្ខព្រួយភ័យខ្លាច។ ខាងចុងនៃគាថានេះ បញ្ជាក់ថា បើបុគ្គលប្រព្រឹត្តធ្វើ ឱ្យគេមានទុក្ខបុគ្គលនោះតែងទទួលនូវអំពើបាប តាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត ជាពិសេស មានអំពើអាក្រក់ខ្លះមានការចងពៀរជាមួយអ្នកដទៃផង។

អំពីដែលធ្វើឱ្យគេមានទុក្ខមានច្រើនយ៉ាង មានបុគ្គលខ្លះក្នុងសង្គមមនុស្សខ្លះ បានទៅលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃរហូតសម្លាប់ម្ចាស់ទ្រព្យថែមទៀត។ ធ្វើឱ្យគេមានទុក្ខ គឺធ្វើឱ្យគេអស់ទ្រព្យសម្បត្តិ ថែមទាំងជីវិតគេត្រូវស្លាប់ទៀត។ ការលួចប្រពន្ធកូនស្រី និងប្ដីរបស់អ្នកដទៃ គឺអ្នកដទៃគេចង់ជួបជុំប្ដី ប្រពន្ធកូនចៅមិនចង់បែកបាក់គ្នាដូចខ្លួនដែរ។ បើអ្នកកាន់អំណាចមិនអនុវត្តឱ្យបានត្រឹមត្រូវតាមមុខងារ នាទីរបស់ខ្លួនតាមរបបប្រជាធិបតេយ្យទេ នឹងធ្វើឱ្យប្រជាពលរដ្ឋមានទុក្ខដោយប្រជាពលរដ្ឋគ្មានសិទ្ធិសេរីភាពពេញបរិបូរណ៌ ដែលជាមូលដ្ឋាននៃសេចក្ដីសុខសន្តិភាព និងការលូតលាស់ខាងសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ បើអ្នកដឹកនាំរដ្ឋបង្កើតសង្គ្រាម នឹងធ្វើឱ្យប្រជាពលរដ្ឋមានទុក្ខលំបាក ដោយការស្លាប់ និងព្រាត់ប្រាស់គ្នា ពិការបាក់ដៃបាក់ជើងជាដើម។

អ្នកសាងបាបកម្មដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬរបស់ជាតិ បើគេចាប់បាននឹងទទួលទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេក៏គេចពុំផុតអំពីទោសទៅមុខទៀតឡើយ។ នៅក្នុងគម្ពីរ ពុទ្ធសាសនានិយាយថា អ្នកដែលលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ និងរបស់ជាតិ នឹងធ្លាក់ទៅសោយទុក្ខ ក្នុងនរក លុះ

សេសសល់ផលកម្ម បើបានកើតមកជាមនុស្សវិញ បើមានទ្រព្យសម្បត្តិក៏ទុកពុំគង់ ចេះតែវិនាសទៅវិញដោយហេតុផ្សេងៗ។ ចំពោះអ្នកដែលសម្លាប់គេដោយខ្លួនឯងក្តី ប្រើគេឱ្យសម្លាប់ក្តី នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាមនុស្ស ឬជាសត្វមានអាយុខ្លី ត្រូវគេសម្លាប់វិញជាច្រើនជាតិ។ បើអ្នកដឹកនាំរដ្ឋដើរផ្លូវខុស នឹងធ្វើឱ្យប្រជាពលរដ្ឋទូទាំងប្រទេសមានទុក្ខ ព្រោះអ្នកដឹកនាំរដ្ឋ ប្រៀបដូចជាអ្នកកាច់ចង្កូតរថយន្ត ឬនាវា បើកាច់ចង្កូតគ្មានការប្រុងប្រយ័ត្ននឹងទទួលគ្រោះថ្នាក់ដល់អ្នកជិះ។ បើអ្នកកាន់អំណាចមិនបានដឹកនាំប្រជាពលរដ្ឋឱ្យបានសុខសន្តិភាព និងមានជីវភាពលូតលាស់ទេ អ្នកកាន់អំណាចនោះនឹងអស់ការគាំទ្រពីប្រជាពលរដ្ឋ ហើយបើមានកំហុសធ្វើបាបប្រជាបលរដ្ឋ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចប្រជាពលរដ្ឋទូទៅដែរ។

ផ្ទុយពីអត្ថន័យខាងលើនេះ បុគ្គលបើចង់បានសេចក្តីសុខដើម្បីខ្លួន មិនត្រូវបៀតបៀនអ្នកដទៃដោយមធ្យោបាយអាក្រក់ណាមួយឡើយ ព្រោះនាំឱ្យចងពៀរនឹងគ្នាផង នាំឱ្យមានទោសទុក្ខទៅមុខផង។ ផ្ទុយទៅវិញ ព្រះពុទ្ធសាសនាសំដែងថា បុគ្គលប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ត្រូវផ្តល់សេចក្តីសុខដល់អ្នកដទៃផង

តាមលទ្ធភាពរបស់ខ្លួន។ ត្រូវប្រើមេត្តា ករុណា អាណិតអាសូរដល់អ្នកដទៃ ឱ្យដូចជាអាណិតអាសូរខ្លួនឯង។ នេះជាហេតុនាំឱ្យបានសុខដោយមិនមានពៀរវេរាជាមួយអ្នកដទៃ។ ចំពោះអ្នកកាន់អំណាចវិញ ដើម្បីកុំឱ្យមានកម្មពៀរវេរាជាមួយប្រជាពលរដ្ឋ ត្រូវតែអនុវត្តកិច្ចការឱ្យបានល្អត្រឹមត្រូវ ប្រកបដោយយុត្តិធម៌ កុំបៀតបៀនប្រជាពលរដ្ឋដោយមធ្យោបាយណាមួយ ផ្ទុយទៅវិញ ត្រូវបម្រើប្រជាពលរដ្ឋដោយចិត្តបរិសុទ្ធ ដោយគោរពជីវិតរបស់ប្រជាពលរដ្ឋឱ្យដូចជាជីវិតរបស់ខ្លួន។ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គប្បីប្រជាពលរដ្ឋ និងអ្នកកាន់អំណាចខ្មែរដែលគោរពព្រះពុទ្ធសាសនា យកទៅពិចារណា ដើម្បីឱ្យខ្មែរគ្រប់ឋានៈរស់នៅជាមួយគ្នាបានសុខសាន្តនៅក្នុងប្រទេសកម្ពុជាមាតុភូមិ៕

## ២០. វប្បធម៌ជាគោលរបស់ជាតិ វិន័យលោកនាថជាគោលសាសនា

ពាក្យខ្មែរថា វប្បធម៌ជាគោលរបស់ជាតិ ចែកចេញជាពីរ គឺ វប្បធម៌ និងពាក្យថា ជាគោលរបស់ជាតិ។ ពាក្យថាវប្បធម៌បាន ដល់ចំណេះចេះដឹង របស់មនុស្សដែលមានលក្ខណៈផ្សេងៗគ្នា សម្រាប់ជាតិ នីមួយៗ។ យ៉ាងណាមិញ ខ្មែរមានលក្ខណៈវប្បធម៌ ពិសេសរបស់ខ្លួន គឺមនោគមវិជ្ជាជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ចរិតលក្ខណៈ ចំណង់ចំណូលចិត្ត ភាសា អក្សរជា ដើម។ ពីដើមខ្មែរមានកាន់សាសនាព្រាហ្មណ៍ ជាមួយព្រះពុទ្ធ សាសនា ប៉ុន្តែក្រោយមកសាសនាព្រាហ្មណ៍បានត្រូវបាត់បង់ ចំណែកព្រះពុទ្ធសាសនានៅគង់វង្ស ដែលជនជាតិខ្មែរច្រើន លើសលប់គោរពបូជាទុកជាសរណៈទីពឹងរបស់ខ្លួន។ សាសនា ព្រាហ្មណ៍បានរត់ជ្រកក្រោមផ្លាកអក្សរសិល្ប៍ និងសិល្បៈផ្សេងៗ។ ពាក្យថាជាគោលរបស់ជាតិ បានសេចក្តីថា ជាគ្រឹះ ជាមូលដ្ឋាន ជាមាគ៌ា ជាជំហររបស់ជាតិ ជាអត្តសញ្ញាណរបស់ជាតិខ្លួន។ បាន សេចក្តីថា ចិត្តគំនិតអធ្យាស្រ័យនៃជាតិខ្មែរមានលក្ខណៈ ស្របទៅ តាមវប្បធម៌របស់ជាតិខ្លួន។ ដូច្នេះ បើវប្បធម៌រលាយជាតិក៏ រលាយដែរ ស្របនឹងពាក្យខ្មែរមួយបទទៀតថា ភាសារលត់ជាតិ

រលាយ។ ការរលាយនេះពុំមែនរលាយរូបរាងកាយទេ គឺរលាយអត្តសញ្ញាណរបស់ជាតិ ដែលមានលក្ខណៈពិសេសជាគ្រឿងសំគាល់។ ឧទាហរណ៍ ខ្មែរមានវប្បធម៌ដែលជាអត្តសញ្ញាណរបស់ខ្លួនពិសេសផ្សេងពីជាតិដទៃ បើលក្ខណៈពិសេសនោះត្រូវរលាយលក្ខណៈគ្រឿងសំគាល់ខ្មែរក៏ត្រូវរលាយដែរ។ តាមពិត លក្ខណៈនៃជាតិនីមួយៗពុំមែនត្រឹមតែសម្គាល់ទៅលើរូបរាងកាយ ពណ៌សម្បុរប៉ុណ្ណោះឡើយ តែសម្គាល់ទៅលើចិត្តគំនិត អធ្យាស្រ័យចរិយាមារយាទ ជាគោលមូលដ្ឋាននេះឯង។ ប៉ុន្តែតាមធម្មជាតិគេពុំអាចបំបាត់វប្បធម៌ដើមរបស់ជាតិនីមួយៗដែលធ្លាប់មានជាផ្នត់គំនិតក្លាយជាទម្លាប់ បានប្រព្រឹត្តអស់កាលជាយូរអង្វែងបានឡើយ តែអាចប្រែប្រួលខ្លះទៅតាមសង្គមបរិយាកាស និងទៅតាមការអប់រំ។ ជាតិមួយដែលអាចរួបរួមគ្នាបានដោយសារតែរូបរាយកាយ ឈាមជ័រ ចិត្តគំនិត ទស្សនវិជ្ជា ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនាដូចគ្នាតែងរត់រកគ្នាទៅជាប្រជាជាតិមួយដោយសរមានវប្បធម៌ជាគោល របស់ជាតិ។ ដូចជាជនជាតិខ្មែរទោះបីមករស់នៅបរទេសក៏នៅតែនឹកដល់ប្រទេសកំណើតរបស់ខ្លួន ខំបន់ស្រន់បួងសួង និងរកមធ្យោបាយធ្វើឱ្យប្រទេសរបស់ខ្លួន និងជនរួមជាតិរបស់ខ្លួនបានសេចក្ដីសុខចម្រើន។ ប៉ុន្តែមាន

ពេលខ្លះមានការខ្វែងគំនិតគ្នាក្នុងការដឹកនាំស្រុកទេស នេះជារឿងធម្មតាបើគិតទៅតាមប្រទេសដែលកាន់របបប្រជាធិបតេយ្យ។

វិន័យលោកនាថជាគោលសាសនា។ អ្នកកាន់ព្រះពុទ្ធសាសនាខ្មែរតែងប្រកាន់គោលមួយថា បើព្រះវិន័យស្ថិតនៅដរាបណា ព្រះពុទ្ធសាសនាតែងស្ថិតនៅដរាបនោះ។ ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទខ្លះឱ្យតម្លៃទៅលើធម៌ប្រសូត្រ ប្រទេសខ្លះឱ្យតម្លៃទៅលើព្រះអភិធម្មថា អាចឱ្យព្រះពុទ្ធសាសនាស្ថិតនៅបាន។ ព្រះវិន័យមានមុខងារកំចាត់ទោសដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងវាចា។ បានសេចក្តីថា កាយនិងវាចាកុំប្រព្រឹត្តអាក្រក់ ដូចកាយកុំកាប់សម្លាប់ កុំលួចប្លន់ វាចាកុំពោលពាក្យកុហក ញុះញង់ បំបែកបំបាក់ជាដើម។ បើមានព្រះវិន័យអាចជៀសវាងការបៀតបៀនគ្នា។ ចំពោះព្រះសង្ឃព្រះពុទ្ធសាសនាដែលមានតម្លៃដ៏ខ្ពង់ខ្ពស់ ជាទីគោរពសក្ការះរបស់ពុទ្ធបរិស័ទ ដោយសារតែព្រះសង្ឃកាន់ព្រះវិន័យ។ ចំណែកពុទ្ធបរិស័ទដែលជឿទុកចិត្តគ្នាដោយសារកាន់ព្រះវិន័យ ដោយហោចមានសីល៥។ លើសពីនេះទៅទៀត មនុស្សគ្រប់រូបដែលរស់នៅជាមួយគ្នាក្នុងសង្គមដូចជាឪពុកម្តាយនិងកូន ស្វាមីនិងភរិយា អ្នកដឹកនាំរដ្ឋនិងប្រជាពលរដ្ឋដែលអាចរស់នៅជាមួយគ្នាបាន ដោយសារតែបំពេញមុខ

ងារបានត្រឹមត្រូវតាមច្បាប់របស់រដ្ឋ បើខ្មែរកាន់ព្រះពុទ្ធសាសនាបានប្រព្រឹត្តត្រឹមត្រូវតាមផ្លូវធម៌។ ដូច្នេះ ព្រះវិន័យអាចកំចាត់ទោសគ្រោតគ្រាត ដែលប្រព្រឹត្តទៅតាមផ្លូវកាយនិងវាចាដែលឃើញសកម្មភាពចេញមកជាក់ស្តែងប៉ះពាល់ដល់អ្នកដទៃ ដូចជាវាយប្រហារ លួចប្លន់ជាដើម។ បើពុំបានអប់រំផ្លូវចិត្តឲ្យល្អទេ ការអត់ទ្រាំមិនធ្វើអំពើបាបតាមផ្លូវកាយវាចានេះ បានក្នុងពេលខ្លះប៉ុណ្ណោះ ពេលណាមួយអាចធ្វើអំពើបាបនេះវិញ។ ដូច្នេះ ត្រូវអប់រំចិត្តជាគោលសំខាន់ ព្រោះចិត្តជាអ្នកបញ្ជាគ្រប់សកម្មភាពល្អអាក្រក់របស់ផ្លូវកាយ និងវាចា។ ការដែលនិយាយថា វិន័យជាគោលសាសនា គឺព្រះពុទ្ធសាសនានេះគ្រាន់តែធ្វើឱ្យព្រះពុទ្ធសាសនាគង់វង្ស ប៉ុន្តែពុំបានទទួលរសជាតិដល់ជម្រៅព្រះពុទ្ធសាសនាឡើយ។ ដូច្នេះ ដើម្បីឱ្យចិត្តបរិសុទ្ធឱ្យដល់ទីបំផុតទុក្ខគេត្រូវតែប្រតិបត្តិតាមវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ទាំងបីនេះដែលមគ្គប្រកបដោយអង្គ ៨ ដែលរួមមកបានដល់សីល សមាធិបញ្ញា។ កាលណាចិត្តបរិសុទ្ធ កាយវាចាក៏បរិសុទ្ធដែរ ព្រោះចិត្តមិនបានបញ្ជាកាយវាចាធ្វើអំពើបាប៕

## ២១. ជំនះខ្លួនឯងជាជំនះប្រសើរបំផុត

មានគាថាមួយបទ នៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាថា សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏ពុំប្រសើរជាងការឈ្នះលើខ្លួនឯងសូម្បីតែម្តងឡើយ បុគ្គលឈ្នះខ្លួនឯង ឈ្មោះថាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត។

តាមផ្ទៃនៃគាថានេះ គេអាចចែកជាពីរគឺជំនះដោយចម្បាំងតាមសមរភូមិផ្លូវលោក និងជំនះដោយចម្បាំងតាមសមរភូមិផ្លូវធម៌។ ចំពោះជំនះដោយចម្បាំងតាមសមរភូមិផ្លូវលោកបានដល់គាថាខាងដើមថា សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងពុំប្រសើរឡើយ។ បានសេចក្តីថា ការឈ្នះអ្នកដទៃដោយកម្លាំងយុទ្ធវិធី ពុំអាចធ្វើឱ្យអ្នកចាញ់សុខចិត្តឡើយ។ សង្គ្រាមអាចកើតឡើងនៅពេលណាមួយទៀតឱកាសដែលអ្នកចាញ់ប្រមូលកម្លាំងបាន។ ដូច្នេះជំនះបែបនេះ បើជាជំនះប្រកបដោយអំពើអយុត្តិធម៌ផង ជាជំនះពុំអាចស្ថិតនៅយូរអង្វែងឡើយ។ ជ័យជំនះឈ្នះដោយអំពើរំលោភឈ្លានពាន ដែលជាការរំលោភសិទ្ធិមនុស្ស ជាជំនះត្រូវត្រឡប់ចាញ់វិញនៅទីបំផុត ។ ឧទាហរណ៍ ហ៊ីត្លែនៃគណបក្សណាស៊ីនៃ

អាល្លឺម៉ង់ ដែលប្រហារជីវិតមនុស្សអស់ជាច្រើននៅក្នុងសង្គ្រាមលោក ទោះបីហ៊ីត្លែរស្លាប់ទៅហើយក៏ដោយ ក៏សមាជិកខ្លះនៃគណបក្សនេះ បានត្រូវតុលាការអន្តរជាតិតាមចាប់យកមកកាត់ទោសរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងករណីដូចគ្នានេះដែរ មេពេជ្ឈឃាតខ្មែរក្រហម ដែលធ្វើឃាតព្រះសង្ឃ និងជនជាតិខ្មែររាប់លាននាក់ ត្រូវតុលាការចម្រុះអន្តរជាតិកាត់ទោស ពុំអាចគេចខ្លួនរួចឡើយ។ នេះជាមេរៀនប្រវត្តិសាស្ត្រប្រាប់មកខ្មែរជំនាន់ក្រោយមកទៀត កុំប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សក្រៅច្បាប់ នឹងត្រូវទទួលទណ្ឌកម្មពុំខានឡើយ។ បើពោលតាមផ្លូវព្រះធម៌នៃព្រះពុទ្ធសាសនាវិញ អ្នកប្រព្រឹត្តអំពើឧក្រិដ្ឋរំលោភសិទ្ធិមនុស្ស បើទោះបីបិទបាំងតុលាការមិនទាន់យកមកកាន់ទោសក៏ដោយ ក៏ទទួលទោសទុក្ខរួចទៅហើយ រស់នៅដោយការភិតភ័យ ដេកផ្លាស់កន្លែង គ្មានសុភមង្គលឡើយ ស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចគេច្រានទម្លាក់។

គាថាក្នុងវគ្គទី២ថា បុគ្គលឈ្នះខ្លួនឯង ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត។ ពាក្យនៃ គាថាខាងចុងនេះ ចាត់ជាជំនះដោយចម្បាំងតាមសមរភូមិផ្លូវធម៌។ ចម្បាំងផ្លូវធម៌ពុំមែនច្បាំងកាប់សម្លាប់អ្នកដទៃទេឡើយ គឺច្បាំងសម្លាប់សេចក្តីអាក្រក់

បានដល់កិលេសតណ្ហាដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនវិញទេ។ ការប្រយុទ្ធគឺការព្យាយាមលះបង់ខ្មាំងសត្រូវបានដល់កិលេសតណ្ហា និងអំពើអាក្រក់គ្រប់យ៉ាង។ បើព្យាយាមល្មមៗពុំអាចលះបានឡើយ។ សមរភូមិផ្លូវធម៌ដែលច្បាំងនឹងកិលេសតណ្ហា មានការពិបាកច្បាំងជាងខ្មាំងសត្រូវ ដែលជាសមរភូមិផ្លូវលោកទៅទៀត។ ប៉ុន្តែកិលេសតណ្ហាណាដែលព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើមច្បាំងឈ្នះ គឺលះបង់បានហើយ នឹងមិនត្រឡប់ចាញ់វិញ គឺមិនត្រឡប់កើតវិញឡើយ។ ចំណែកមនុស្សសត្វដែលនៅជាបុថុជ្ជន ពុំងាយលះបានឡើយ ព្រោះពុំទាន់ឃើញទោសច្បាស់នូវកិលេសតណ្ហា បើលះបានក្នុងពេលខ្លះក៏ពេលក្រោយអាចកើតឡើងវិញ ព្រោះបញ្ញាដែលកើតពីការប្រតិបត្តិនូវព្រះធម៌នៅទន់ខ្សោយ។ បានជាព្រះសម្ពុទ្ធបង្រៀនឱ្យមនុស្សសត្វលះនូវកិលេសតណ្ហានេះ ព្រោះជាឫសគល់នាំឱ្យមនុស្សសត្វសាងបាបកម្ម ដែលនាំឱ្យមានវិបាកវិលស្លាប់ វិលកើតក្នុងសង្សារវដ្តរកទីបំផុតគ្មាន។

គាថានេះ ជាការប្រៀបធៀបគ្នារវាងជំនះដោយការប្រកួតប្រជែងគ្នារហូតធ្វើចម្បាំងកាប់សម្លាប់គ្នាជាជំនះពុំប្រសើរ ព្រោះនាំឱ្យចងគំនំនឹងគ្នាទៅវិញទៅមក ពុំបានសេចក្តីសុខឡើយ។

ចំណែកជំនះ ដែលកើតពីការលះបង់នូវកិលេសតណ្ហា អវិជ្ជា ដែលស្ថិតនៅក្នុងចិត្តរបស់មនុស្សសត្វ ជាជំនះប្រសើរ ព្រោះនាំឱ្យរួចចាកទុក្ខ មានជាតិទុក្ខជាដើម។ គាថាដ៏មានប្រយោជន៍សំខាន់នេះ បានប្រាប់ដល់មនុស្សសត្វថា បើគេស្អប់ទុក្ខចង់បានសេចក្តីសុខ គេត្រូវតែអប់រំចិត្តឱ្យស្ងប់អំពើបាប លះបង់ការបៀតបៀន គឺឈ្នះនូវសេចក្តីអាក្រក់របស់ខ្លួន។ ដូចជាព្រះសម្ពុទ្ធឈ្នះមារ ពុំមែនឈ្នះមារបានដល់ការឈ្នះដល់អ្នកដទៃឡើយ គឺឈ្នះកិលេសមារ ដែលស្ថិតនៅក្នុងព្រះទ័យព្រះអង្គ។ ការឈ្នះអវិជ្ជា តណ្ហា ឧបាទាន និងកម្មដែលជាហេតុនាំឱ្យកើតទុក្ខនេះហើយ ទើបសេចក្តីទុក្ខគឺការកើតឡើងនៃខន្ធ ៥ ក៏ត្រូវរលត់៕